# ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣

❋❋❋✧❋❋❋

## ១. សេចក្តីផ្តើម

**១.** ក្រោមម្លប់នៃសុខសន្តិភាព និងស្ថិរភាពនយោបាយក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ដែលជាសមិទ្ធផលមិនអាចកាត់ថ្លៃបាន នាំមកជូនប្រជាជនកម្ពុជា ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ទោះជាស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃវិបត្តិកូវីដ-១៩, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងវិធានការជាបន្តបន្ទាប់ ទាំងក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម ដើម្បីពង្រឹងការអភិវឌ្ឍវិស័យឯកជន និងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ទាក់ទាញការវិនិយោគ និងពាណិជ្ជកម្ម សំដៅពន្លឿនការធ្វើពិពិធកម្ម និងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា, និងជាពិសេស បន្តទ្រទ្រង់និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ ឆ្នាំ ២០២៣ គឺជាដំណាក់កាលដែលកម្ពុជាបន្តការងារស្តារសង្គម-សេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ និងត្រូវបោះជំហានលើមាគ៌ានៃគន្លងអភិវឌ្ឍន៍ថ្មី បន្ទាប់ពីរងការប៉ះទង្គិចយ៉ាងខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ ខណៈដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភានឹងត្រូវបានបញ្ចប់ ។

**២.** ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមក, រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្អន់កិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញការអនុវត្តការដ្ឋានកែទម្រង់សំខាន់ៗ ជាពិសេស ការអនុវត្ត និងសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី ៤** ដើម្បី **កំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣** សំដៅជំរុញកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ជាក់ស្តែង, រាជដ្ឋាភិបាលបានដោះស្រាយជាបន្តបន្ទាប់នូវបញ្ហាប្រឈមសំខាន់ៗដែលបណ្តាវិនិយោគិន និងធុរជនបានជួបប្រទះក្នុងគ្រប់វិស័យ ដើម្បីបង្កភាពងាយស្រួល និងបង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម និងវិនិយោគ តាមរយៈការដាក់ឱ្យអនុវត្តនូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ក្របខណ្ឌគោលនយោបាយសង្គម-សេដ្ឋកិច្ចឌីជីថលកម្ពុជា ២០២១-២០៣៥, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី

សម្រាប់ឆ្នាំ ២០២១-២០២៣, និង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧ ជាដើម ។ ជាងនេះទៅទៀត, កិច្ចខិតខំប្រឹងប្រែង ប្រកបដោយភាពបុរេសកម្មរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវវិធានការរក្សាលំនឹងសង្គម-សេដ្ឋកិច្ចទាន់ពេលវេលាជាបន្តបន្ទាប់ ជាមួយនឹងការរួបរួមគ្នាក្នុងសង្គម តាមរយៈការចូលរួមយ៉ាងខ្លាំងក្លារបស់ប្រជាជនកម្ពុជាក្នុងស្មារតីប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ បានបង្កើតនូវ **ភាពស៊ាំសហគមន៍** និងបានចូលរួមពង្រឹងមូលដ្ឋានគ្រឹះសម្រាប់កិច្ចអភិវឌ្ឍឡើងវិញឱ្យកាន់តែរឹងមាំសម្រាប់កម្ពុជា ឈានទៅរកដំណើរការស្តារ និងពន្លឿនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពជឿជាក់ ។ **ឆ្នាំ ២០២៣ នេះ ជាឆ្នាំដែលរាជរដ្ឋាភិបាលត្រូវបន្តដាក់ចេញនូវវិធានការបន្ថែម ដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាពដែលនៅសេសសល់ និងការវាយតម្លៃ លើវឌ្ឍនភាពការងារជារួមក្រោមរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ក្នុង នីតិកាលទី ៦ នៃរដ្ឋសភា ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលសម្រាប់អាណត្តិក្រោយ ។**

**៣.** ក្នុងក្របខណ្ឌសកល, ស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ បាននិងកំពុងមានភាពធូរស្បើយ ដែលអាចអនុញ្ញាតឱ្យបណ្តាប្រទេសជាច្រើន នៅក្នុងតំបន់ និងពិភពលោក បើកប្រទេសឡើងវិញ និងអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច ចាប់ផ្តើមដំណើរការឡើងវិញជាបណ្តើរៗ ។ ជាការពិត, ដោយសារវឌ្ឍនភាពយ៉ាងលឿននៃបច្ចេកវិទ្យាទំនើបក្នុងវិស័យវេជ្ជសាស្ត្រ វ៉ាក់សាំងកូវីដ-១៩ និងថ្នាំព្យាបាលជាច្រើនប្រភេទត្រូវបានរកឃើញជាមួយនឹងប្រសិទ្ធភាពខ្ពស់ក្នុងការការពារការឆ្លងជំងឺកូវីដ-១៩ ហើយត្រូវបានអនុញ្ញាតឱ្យផលិតក្នុងទ្រង់ទ្រាយធំដោយអង្គការសុខភាពពិភពលោក (WHO) សម្រាប់ចែកចាយទូទាំងសកលលោក ។ ជាមួយគ្នានេះ, បណ្តាប្រទេសជាច្រើនបានជំរុញការអនុវត្តនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញសម្រាប់ប្រជាជនខ្លួន ប៉ុន្តែ ក្នុងល្បឿនផ្សេងៗគ្នា ទៅតាមលទ្ធភាពនៃការទទួលបាន និងយន្តការចែកចាយក្នុងប្រទេសនីមួយៗ ។ ជារួម, ដំណើរការចាក់វ៉ាក់សាំងជាសកលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរជាមួយនឹងប្រជាជនក្នុងពិភពលោក ប្រមាណ ជាង ៦៥% បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងហោចណាស់មួយដូស ខណៈដែលពិភពលោកបាន និងកំពុងរៀនសម្របខ្លួននឹងការរស់នៅជាមួយជំងឺកូវីដ-១៩នេះ តាមគន្លងប្រក្រតីភាពថ្មី ។ ការណ៍នេះបានក្លាយជាមូលដ្ឋានយ៉ាងចាំបាច់មិនអាចខ្វះបានក្នុងការគិតគូរ និងការដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយនានា ដើម្បីស្តារ សេដ្ឋកិច្ចឡើងវិញ ។ ជាមួយគ្នានេះ, សកម្មភាពសេដ្ឋកិច្ច ជាពិសេស ពាណិជ្ជកម្មអន្តរជាតិ ផលិតកម្ម និងច្រវាក់ផ្គត់ផ្គង់ បានចាប់ផ្តើមដំណើរការជាបណ្តើរៗទៅតាមតម្រូវការជាក់ស្តែង ដែលនេះបាននិងកំពុងឆ្លុះបញ្ចាំងពីការបន្ស៊ាំខ្លួន ទៅនឹងការរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងសង្គម ទាំងធុរជន វិនិយោគិន និងជាពិសេស ប្រជាជនទូទៅ ។

**៤.** ឈរលើមូលដ្ឋាននេះ, កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២៣ ត្រូវបានវាយតម្លៃឡើងវិញថានឹងសម្រេចបានក្នុងអត្រា ៣,៦% ដែលឆ្លុះបញ្ចាំងតាមរយៈនិន្នាការកើនឡើងនៃតម្រូវការសកល ទាំងទំនិញ និងសេវា, វិហ្វូវិនិយោគ និងការធ្វើដំណើររបស់ប្រជាជនលើសកលលោក ទាំងសម្រាប់គោលបំណងដើរកម្សាន្ត និងធុរកិច្ច ។ យ៉ាងណាមិញ, ការបន្តងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចសកលទាបជាងការរំពឹងទុកនេះ បណ្តាលមកពីកត្តាមួយ

ចំនួន រួមមាន ១). សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលបង្កផលប៉ះពាល់ដល់ថ្លៃទំនិញសកល, វិហ្វពាណិជ្ជកម្ម, ស្ថានភាពហិរញ្ញវត្ថុ និងវិហ្វវិនិយោគសកល, ២). ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដោយបណ្ដាប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ ដែលធ្វើឱ្យអត្រាការប្រាក់សកលបន្តកើនឡើង, ៣). ការដកចេញនូវវិធានការគាំទ្រ ជាបន្តបន្ទាប់របស់បណ្ដាប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍, ៤). ការថមថយសេដ្ឋកិច្ចជារចនាសម្ព័ន្ធ និងគោលនយោបាយគ្មានកូវីដ-១៩ (Zero-Covid Policy) របស់ប្រទេសចិន, និង ៥). គម្លាតធំនៃការបែងចែកវ៉ាក់សាំងកូវីដ-១៩ ក្នុងកម្រិតសកល ដែលអាចបង្កលទ្ធភាពដល់ការបង្កើតនូវវីរុសបំប្លែងខ្លួនប្រភេទថ្មីផ្សេងទៀត ។ ក្នុងបរិបទនេះ, ក្នុងរយៈពេលខ្លី និងមធ្យម, រដ្ឋាភិបាលនៅគ្រប់បណ្ដាប្រទេសនានាលើសកលលោកនឹងផ្ដល់អាទិភាពខ្ពស់លើការបង្កើននូវចំណាយសម្រាប់វិស័យសុខាភិបាល, ការកែសម្រួលកម្មវិធីជំនួយសង្គមឱ្យកាន់តែចំទិសដៅ, ការពន្លឿនការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច, ការជំរុញការបណ្ដុះបណ្ដាលជំនាញឡើងវិញ និងការជួយសម្រួលការផ្លាស់ប្ដូរការងារឱ្យស្របទៅនឹងបរិការណ៍ថ្មី ។

**៥.** ទោះជាយ៉ាងនេះក្ដី, បច្ចុប្បន្ននេះ ពិភពលោកទាំងមូល ក៏កំពុងតែហ៊ុមព័ទ្ធដោយហានិភ័យស្រួចស្រាល់មួយចំនួន ដែលកំពុងវិវត្តយ៉ាងឆាប់រហ័សផងដែរ ។ ការប្រែប្រួលអាកាសធាតុ, ភាពតានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយតំបន់ ជាពិសេស សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ព្រមទាំងសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាចនានា អាចមានលទ្ធភាពជះឥទ្ធិពលអវិជ្ជមានដែលមិនអាចប៉ាន់ប្រមាណបាន និងអាចបង្កើតជាភាពស្មុគស្មាញ និងភាពរឹករវរ ដល់ការអភិវឌ្ឍក្នុងតំបន់ និងសកល សម្រាប់រយៈពេលខ្លី និងមធ្យម ។ បន្ថែមលើនេះ, ការកើនឡើងនូវការព្រួយបារម្ភលើសន្តិភាព, ស្ថិរភាព និងសន្តិសុខ ជាមួយនឹងនិន្នាការពហុប៉ូល, ការប្រកួតប្រជែងដណ្ដើមផលប្រយោជន៍ និងការប្រែប្រួលនៃតុល្យភាពអំណាចសកល និងតំបន់ ព្រមទាំងនិន្នាការឯកតោភាគីនិយមក្នុងការអនុវត្តវិធានការយោធា, សេដ្ឋកិច្ច, ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ បាននិងកំពុងធ្វើឱ្យប៉ះពាល់ដល់ចរន្តសកលភាវូបនីយកម្ម, សណ្ដាប់ធ្នាប់អន្តរជាតិ និងពហុភាគីនិយមផ្អែកលើវិធានច្បាប់ ផងដែរ។

**៦.** សម្រាប់កម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមកនេះ, រាជរដ្ឋាភិបាលបានខិតខំយ៉ាងសស្រាក់សស្រាំ ប្រកបដោយស្មារតីបុរេសកម្ម ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញនូវវិធានការសុខាភិបាល, វិធានការរដ្ឋបាល និងវិធានការជំរុញសកម្មភាពសេដ្ឋកិច្ច ដែលឈរលើគោលការណ៍ជាក់ស្ដែងនិយម និងទន់ភ្លន់ប៉ុន្តែម៉ឺងម៉ាត់ ដោយបត់បែនទាន់ពេលវេលា ទៅតាមសភាពការណ៍ និងភូមិសាស្ត្រ ។ រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំងជា **វិធានការយុទ្ធសាស្ត្រគន្លឹះ** ហើយកម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសដែលមានអត្រាគ្របដណ្ដប់ខ្ពស់ខ្លាំងនៃចំនួនប្រជាជនទទួលបានវ៉ាក់សាំងកូវីដ-១៩ ក្នុងកម្រិតសកល បើទោះបីជាធនធានមានកម្រិតក៏ដោយ ។ លទ្ធផលជាក់ស្ដែងនេះបានជំរុញឱ្យកម្ពុជាឈានទៅសម្រេចបាននូវ **"ភាពស៊ាំសហគមន៍"** យ៉ាងឆាប់រហ័ស និងជាកត្តាស្នូលសម្រាប់ការបើកប្រទេសឡើងវិញ ព្រមទាំងអាចមានលទ្ធភាពជំរុញកិច្ចដំណើរការសង្គម-សេដ្ឋកិច្ច ឆ្ពោះទៅរកប្រក្រតីភាពថ្មីនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ

កម្ពុជាទូទៅ ។ ទន្ទឹមនេះ, ជ័យជំនះលើសមរភូមិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គឺជាផ្លែផ្កានៃការដាក់ចេញនូវវិធានការឆ្លើយតបភ្លាមៗ និងបានទាន់ពេលវេលា ដោយរាជរដ្ឋាភិបាល រួមមាន វិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច ចំនួន ១០ ជុំ សំដៅដោះស្រាយបញ្ហាចំពោះមុខ, គាំទ្រសកម្មភាពធុរកិច្ច-ពាណិជ្ជកម្ម និងការគាំពារអាយុជីវិត និងទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជា ជំរុញកំណើន និងបង្កើនភាពធន់សេដ្ឋកិច្ច-សង្គម ។ ដើម្បីគាំទ្រដល់ការអនុវត្តវិធានការអន្តរាគមន៍ទាំងនេះ, រាជរដ្ឋាភិបាលក៏បានធ្វើវិចារណកម្មថវិកា និងអាទិភាវូនីយកម្មមុខសញ្ញាចំណាយជាប្រចាំ សំដៅតម្រង់ទិសធនធានឱ្យកាន់តែចំគោលដៅ និងបានអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងបរិការណ៍នៃការថមថយចំណូលជារួម ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកាប្រមាណ **៨២៤ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២០ និង **១ ២៩១ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២១ សម្រាប់ការអនុវត្តវិធានការអន្តរាគមន៍បន្ទាន់ៗ ក្នុងការដោះស្រាយផលប៉ះពាល់ទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ ហើយបានវិភាជថវិកាចំនួន **៩៨៩ លានដុល្លារអាមេរិក** បន្ថែមទៀត សម្រាប់ការបន្តអនុវត្តវិធានការអន្តរាគមន៍ក្នុងឆ្នាំ ២០២២ នេះ ។ ជារួម, ភាពជោគជ័យនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ បានល្អប្រសើរ ព្រមទាំងនិន្នាការធូរស្រាលនៃជំងឺកូវីដ-១៩ ជាសកល បានអនុញ្ញាតឱ្យកម្ពុជាអាចបិទបញ្ចប់នូវ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**" ហើយបានបើកប្រទេស និងដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុកពេញលេញឡើងវិញចាប់ពីចុងឆ្នាំ ២០២១ មក ។

**៧.** ក្នុងឆ្នាំ ២០២៣, ស្របទៅនឹងនិន្នាការសកល, សេដ្ឋកិច្ចកម្ពុជារំពឹងថា នឹងបន្តឈានទៅរកវិថីកំណើនឡើងវិញ ដោយសារការសម្រេចបាននូវភាពស៊ាំសហគមន៍ ក៏ដូចជាការសម្របខ្លួនទៅនឹងគន្លងប្រក្រតីភាពថ្មីរបស់ប្រជាជនទូទៅ ក៏ដូចជាអាជីវកម្ម បើទោះបីជាប្រឈមនឹងហានិភ័យមួយចំនួនក៏ដោយ ។ ចន្ទល់សេដ្ឋកិច្ចស្ទើរគ្រប់វិស័យត្រូវបានរំពឹងថានឹងមានកំណើនឡើងវិញគួរឱ្យកត់សម្គាល់ ដោយសារនិន្នាការល្អប្រសើរនៃសេដ្ឋកិច្ចសកល និងគោលនយោបាយជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុក ។ ប៉ុន្តែ, កម្ពុជា, ដែលជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនិន្នាការសេដ្ឋកិច្ចតំបន់ និងសកល, ក៏នៅជួបប្រទះនឹងហានិភ័យ និងភាពមិនប្រាកដប្រជាមួយចំនួន គួបផ្សំនឹងបញ្ហាប្រឈមកាន់តែស្មុគស្មាញជាងមុន ។ ការណ៍នេះទាមទារឱ្យមានការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធវ៉ាំរ៉ៃនានា និងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តវិធានការដែលបានដាក់ចេញ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេស ជំរុញសកម្មភាពផលិតកម្មក្នុងស្រុកឱ្យកាន់តែមានសម្ទុះរីកចម្រើនខ្លាំងក្លាផងដែរ ។

**៨.** ជារួម សេដ្ឋកិច្ច និងពាណិជ្ជកម្មសកល បាននិងកំពុងមានការប្រែប្រួលជារចនាសម្ព័ន្ធ ក្រោមឥទ្ធិពលនៃវិបត្តិ និងនិន្នាការនានាដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស, ដែលការណ៍នេះទាមទារឱ្យកម្ពុជាត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ ក្នុងការសម្របខ្លួនឱ្យទាន់ពេល និងចាប់យកកាលានុវត្តភាពដែលលេចឡើង ដើម្បីពន្លឿនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ខ្លួន មានជាអាទិ៍ ÷

**(១)-ការបន្តអភិវឌ្ឍវិស័យសុខាភិបាល និងការសម្រេចបាននូវអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ខ្ពស់ទូទាំងសកលលោក នៅតែជាកត្តាគន្លឹះក្នុងការបញ្ចប់វិបត្តិជំងឺកូវីដ-១៩ ÷** ការបន្តលេចឡើងនូវវីរុសបំប្លែងខ្លួនប្រភេទថ្មីបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការរបស់គ្រប់បណ្តាប្រទេស ដើម្បីលុបបំបាត់នូវគម្លាតរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ ក្នុងការទទួលបានវ៉ាក់សាំងកូវីដ-១៩, ការធ្វើតេស្ត, ការព្យាបាល និងបរិក្ខារវេជ្ជសាស្ត្រ គួបផ្សំនឹងការអភិវឌ្ឍប្រព័ន្ធសុខាភិបាលរឹងមាំ ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបទៅនឹងហានិភ័យសុខភាពសាធារណៈនាពេលអនាគត ។

**(២)-ការបន្តផ្លាស់ប្តូរកាន់តែលឿននូវនិម្មាបនកម្មសេដ្ឋកិច្ចសកល និងការប្រែប្រួលនៃចរន្តសកលភាវូបនីយកម្ម កំពុងបង្ហាញកាន់តែប្រចក្សនូវរបត់ថ្មីមួយនៃការអភិវឌ្ឍ ទាំងក្នុងក្របខណ្ឌតំបន់ និងក្របខណ្ឌសកល÷** ការរីករាលដាលនៃជំងឺកូវីដ-១៩ បានកំពុងពន្លឿនការកែសម្រួលឡើងវិញជាយុទ្ធសាស្ត្រនូវខ្សែច្រវ៉ាក់ផ្គត់ផ្គង់ និងផលិតកម្មតំបន់ និងសកល ដូចជា ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម (Reshoring and Relocation) សំដៅធានាចីរភាពនៃខ្សែច្រវ៉ាក់ផលិតកម្ម និងកិច្ចអភិវឌ្ឍន៍ ដែលការណ៍នេះនឹងនាំមកនូវការវិនិយោគបន្ថែមក្នុងតំបន់ជាពិសេស អាស៊ាន ដែលមានសក្តានុពលខ្ពស់ ។ ទន្ទឹមនេះ, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាច គួបផ្សំនឹងភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយតំបន់ និងសកល ដូចជាការលេចឡើងនូវសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ក៏បានដាក់សម្ពាធមួយកម្រិតទៀតទៅលើការកែសម្រួលច្រវ៉ាក់ផលិតកម្ម និងផ្គត់ផ្គង់ក្នុងតំបន់ និងសកលនេះ ផងដែរ ។ ជានិន្នាការទៅមុខ, ប្រទេសជាច្រើននឹងផ្តល់អាទិភាពខ្ពស់ទៅលើការអភិវឌ្ឍដោយពឹងអាស្រ័យលើខ្លួនឯង (Self-sufficient) ជាពិសេស លើការផលិតទំនិញយុទ្ធសាស្ត្រ ដូចជាស្បៀង, សព្វាវុធ និងវត្ថុធាតុដើមសម្រាប់ឧបករណ៍អេឡិចត្រូនិក និងឌីជីថល ជាដើម ក្នុងការរក្សាសន្តិសុខជាតិ និងសន្តិសុខស្បៀង ដោយកាត់បន្ថយកាន់តែខ្លាំងក្នុងការចូលរួមក្នុងចរន្តសកលភាវូបនីយកម្ម ។

**(៣)-ការសម្របខ្លួនកាន់តែលឿនទៅនឹងនិន្នាការថ្មីៗ ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ បានក្លាយជាអាទិភាពនៃរបៀបវារៈសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច÷** ឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល ក្នុងសេដ្ឋកិច្ច និងសង្គម គួបផ្សំនឹងវឌ្ឍនភាពយ៉ាងលឿននៃការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងស្វ័យប្រវត្តិកម្ម នៅតែបន្តទទួលបានការយកចិត្តទុកដាក់ខ្ពស់ និងមានតួនាទីកាន់តែសំខាន់ឡើងៗក្នុងសកម្មភាពសេដ្ឋកិច្ច, ធុរកិច្ច និងអភិបាលកិច្ច ។ ជាមួយគ្នានេះ, ការបង្កើនការយកចិត្តទុកដាក់ជាងមុនលើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ដូចជា ការជំរុញការធ្វើអន្តរកាលថាមពល (Energy Transition), ការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង និងការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព (Sustainable Finance) តាមរយៈការបង្កើនការចូលរួមពីវិស័យឯកជន, ក៏បានក្លាយជាអាទិភាពមួយយ៉ាងសំខាន់ ដែលមិនអាចខ្វះបាន សម្រាប់ជំរុញការស្តារ និងជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច, ជាពិសេស ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព,បរិយាប័ន្ន និងភាពធន់ សម្រាប់រយៈពេលមធ្យម និងវែង ។

**(៤)-ការកើនឡើងនូវតម្រូវការសម្រាប់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងភាពធន់÷** វិបត្តិជំងឺកូវីដ-១៩ បានជំរុញឱ្យរដ្ឋាភិបាលគ្រប់បណ្តាប្រទេស បង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍនូវប្រព័ន្ធ

គាំពារសង្គម ដើម្បីកាត់បន្ថយផលវិបាកដែលនៅសេសសល់ (Scarring Effects) មកលើប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសក្រុមប្រជាជនក្រីក្រ, ជនងាយរងគ្រោះ និងមនុស្សវ័យចំណាស់ និងបន្តដោះស្រាយនូវបញ្ហានានា ដូចជា ការធ្លាក់ចុះផលិតភាពសកល, ការបាត់បង់ការងារ, ការកើនឡើងនូវអត្រាភាពក្រីក្រ និងវិសមភាពសង្គម ជាដើម ។ ជាងនេះទៅទៀត, ការបង្កើនវិនិយោគក្នុងវិស័យសង្គមកិច្ច ជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍ គឺជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការបង្កើនផលិតភាពសេដ្ឋកិច្ច និងការពង្រឹងភាពធន់សង្គម ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីគ្រោះអាសន្ននាពេលអនាគត ខណៈដែលការពង្រឹងការអនុវត្តយុទ្ធសាស្ត្រគៀរចំណូល ជាពិសេស ការកែលម្អអភិបាលកិច្ចនៃការគៀរ និងគ្រប់គ្រងចំណូលក្នុងស្រុក គឺជាកិច្ចការគន្លឹះ ដើម្បីបំពេញបន្ថែមនូវតម្រូវការធនធានសម្រាប់កិច្ចអភិវឌ្ឍលើអាទិភាពទាំងនេះ ។ ទន្ទឹមនេះ ការយកចិត្តទុកដាក់លើការពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ និងការជំរុញការអនុវត្តបច្ចេកវិទ្យាឌីជីថល ក្នុងកិច្ចការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងការបង្កើនកិច្ចសម្រួលពាណិជ្ជកម្ម ក៏ជាអាទិភាពមួយយ៉ាងសំខាន់ ក្នុងការពង្រឹងភាពធន់ ។

**៩.** ក្នុងបរិបទនេះ, ខណៈដែលកម្ពុជាកំពុងស្តារ និងកសាងមូលដ្ឋានអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ ដើម្បីបោះជំហានទៅលើគន្លងអភិវឌ្ឍន៍ថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល, រាជរដ្ឋាភិបាលនឹងដើរតួនាទីកាន់តែសំខាន់ ដែលមិនអាចខ្វះបាន ក្នុងការធានាបាននូវនិរន្តរភាពនៃកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឆ្លើយតបទៅនឹងវិបត្តិ ដូចដែលវិបត្តិជំងឺកូវីដ-១៩ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ ។ ជាងនេះទៅទៀត, រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើនការយកចិត្តទុកដាក់ទ្វេដង ទាំងក្នុងការដោះស្រាយបញ្ហារចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកកម្ពស់នូវភាពធន់ទៅនឹងវិបត្តិ តាមរយៈការពង្រឹងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចគ្រប់គ្រង និងដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ចនានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងរយៈពេលវែង ។

**១០.** ជារួម ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ នេះជាមូលដ្ឋានសម្រាប់ការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៣ និងផ្តល់ទិសដៅគោលនយោបាយបន្ថែមសម្រាប់ការបន្តពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ច, បន្តចាប់យកកាលានុវត្តភាពថ្មីៗ ដើម្បីលើកកម្ពស់កំណើនប្រកបដោយចីរភាព និងដែលកាន់តែមានពិពិធកម្ម, ជាពិសេស កសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច ដែលជាលក្ខខណ្ឌសម្រាប់តម្រង់ទិសក្នុងការរៀបចំរបៀបវារៈអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភាខាងមុខនេះ ក្នុងបរិបទសកលដែលបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ។

## ២. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២១

**១១.** ក្នុងឆ្នាំ ២០២១, សេដ្ឋកិច្ចសកលបានចាប់ផ្តើមងើបឡើងវិញ ក្នុងអត្រាប្រមាណ ៦,១% បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ ២០២០ ដោយសារការដាក់ចេញនូវគោលនយោបាយគាំទ្រផ្សេងៗជាច្រើន ទាំងផ្នែករូបិយវត្ថុ និងផ្នែកសារពើពន្ធ គួបផ្សំនឹងការបន្តចាក់វ៉ាក់សាំងកូវីដ-១៩ បានកាន់តែទូលំទូលាយ ទាំងក្នុងកម្រិតតំបន់ និងសកល សំដៅកាត់បន្ថយផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងជំរុញកំណើនសេដ្ឋកិច្ច ។ ស្របគ្នា

ទៅនឹងបណ្តាប្រទេសនានាលើសកលលោក, សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញ ក្នុងអត្រាកំណើនទាប ៣,០% ក្នុងឆ្នាំ ២០២១ ពីកំណើនអវិជ្ជមាន -៣,១% ក្នុងឆ្នាំ ២០២០ ដែលគាំទ្រដោយការអនុវត្តវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងជាពិសេស ការងើបឡើងវិញក្នុងល្បឿនលឿននៃវិស័យឧស្សាហកម្ម និងកំណើនល្អប្រសើរនៃវិស័យកសិកម្ម ។ ក្នុងនោះ, វិស័យឧស្សាហកម្ម សម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រា ៨,៦% ទោះបីជាទទួលរងការបន្ទុចបង្អាក់ពី "ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ" ដែលគាំទ្រដោយការងើបឡើងវិញនៃអនុវិស័យកាត់ដេរ និងការបន្តកំណើនល្អប្រសើរនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលអនុវិស័យសំណង់ក៏បានងើបឡើងវិញផងដែរ ប៉ុន្តែក្នុងល្បឿនយឺត ។ ទន្ទឹមនេះ, វិស័យកសិកម្មក៏សម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រា ១,១% រុញច្រានដោយកំណើនល្អនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ ខណៈដែលអនុវិស័យនេសាទមានកំណើនធ្លាក់ចុះ ។ ទោះជាយ៉ាងនេះក្តី, វិស័យសេវាកម្មបន្តមានកំណើនធ្លាក់ចុះ ក្នុងអត្រា -១,៩% ដោយសារការបន្តធ្លាក់ចុះនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ។

**១២.** បើទោះបីស្ថានភាពសេដ្ឋកិច្ចបានងើបឡើងមកវិញ ក្នុងអត្រាកំណើនវិជ្ជមានយ៉ាងណាក្តី, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជានៅបន្តទទួលរងសម្ពាធគួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង, ការប្រមូលចំណូលក្នុងស្រុកសម្រាប់ឆ្នាំ ២០២១ (តួលេខបណ្តោះអាសន្ន) សម្រេចបានប្រមាណ ២០,៥៣% នៃ ផសស ពោលគឺមានការថមថយ ប្រមាណ -៤,៦% ធៀបនឹងលទ្ធផលឆ្នាំ ២០២០ ដោយសារការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ ជាពិសេស ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ស្របពេលដែលរាជរដ្ឋាភិបាលបន្តអនុគ្រោះពន្ធ និងកាតព្វកិច្ចមិនមែនសារពើពន្ធ ដល់វិស័យមួយចំនួនដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនេះ ។ ចំពោះមុខនៃការបន្តថមថយចំណូលនេះ, ការអនុវត្តចំណាយក្នុងឆ្នាំ ២០២១ មានទំហំធំរហូតដល់ទៅ ៣១,៥៩% នៃ ផសស (តួលេខបណ្តោះអាសន្ន) សមាមាត្រនឹង ១០៩,០% នៃច្បាប់ថវិកា ពោលគឺ កើនឡើង ១១,១% ធៀបនឹងឆ្នាំ ២០២០ ។ ក្នុងនោះ, រាជរដ្ឋាភិបាលបានរក្សាកម្រិតប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធស្មើនឹងកម្រិតឆ្នាំ ២០២០ ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំង ធ្វើវិចារណកម្មលើមុខចំណាយលែងចាំបាច់នានា សំដៅបង្វែរថវិកាសម្រាប់ជួយទ្រទ្រង់ការដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ដែលមានទំហំរហូតដល់ទៅ ១ ២៩១ លានដុល្លារអាមេរិក ។ ជាលទ្ធផល, ជាមួយនឹងការកើនឡើងនូវចំណាយអន្តរាគមន៍យ៉ាងគំហុកនេះ ខណៈដែលចំណូលមានការធ្លាក់ចុះ, ឱនភាពថវិកាក្នុងឆ្នាំ ២០២១ បានកើនឡើងខ្ពស់រហូតដល់ទៅ -១១,០៦% នៃ ផសស ។

## ៣. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**១៣.** ក្នុងឆ្នាំ ២០២២ និង ២០២៣, កំណើនសេដ្ឋកិច្ចសកលត្រូវបានរំពឹងថានៅបន្តនិន្នាការកើនឡើង ប៉ុន្តែមានសន្ទុះយឺតជាងការរំពឹងទុក ដោយសារការប៉ះពាល់ដោយផ្ទាល់ និងប្រយោលនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ។ ឈរលើមូលដ្ឋាននេះ, កំណើនសេដ្ឋកិច្ចសកលរំពឹងថានឹងសម្រេចបានក្នុងអត្រា ៣,៦% ដូចគ្នាសម្រាប់ឆ្នាំ ២០២២ និង ២០២៣ ទាបជាងការព្យាករ កាលពីដើមឆ្នាំ ប្រមាណ ០,៨ និង ០,២ ពិន្ទុភាគរយ រៀងគ្នា

ក្រោមការសន្មតមួយចំនួន ដូចជា÷ ១). ជម្លោះនេះនឹងស្ថិតតែនៅក្នុងប្រទេសអ៊ុយក្រែន ដោយគ្មានការផ្ទុះឡើងនៅតាមតំបន់ទីតាំងភូមិសាស្ត្រនយោបាយផ្សេងទៀត និង ២). ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចផ្សេងៗមកលើរុស្ស៊ី លើកលែងតែការនាំចេញថាមពល គួបផ្សំនឹងការថមថយយ៉ាងសន្សឹមៗនៃផលប៉ះពាល់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ក្នុងអំឡុងឆ្នាំ ២០២២ ។ ទោះជាយ៉ាងនេះក្តី, ទំហំសេដ្ឋកិច្ចសកលជារួម នឹងស្ថិតក្រោមកម្រិតមុនវិបត្តិជំងឺកូវីដ-១៩ រហូតដល់ឆ្នាំ ២០២៦ ។ ក្នុងនោះ, ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍ ប្រឈមនឹងស្លាកស្នាមសេដ្ឋកិច្ច (Economic Scarring) ក្នុងទំហំធំជាងប្រទេសអភិវឌ្ឍន៍ ដោយសារគម្លាតធំនៃអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ និងទំហំនៃគោលនយោបាយគាំពាររបស់រដ្ឋាភិបាលនីមួយៗ ។ ជារួម, ទស្សនវិស័យសេដ្ឋកិច្ចសកលបាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាមួយចំនួន ដែលនៅតែអាចបន្តយាយីមកលើការខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសនានាលើសកលលោក រួមមាន ១). ការបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន និងការបន្តដាក់ទណ្ឌកម្មសេដ្ឋកិច្ចបន្ថែមមកលើរុស្ស៊ី, ២). កំណើនយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចចិន ដោយសារ ការកែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយគ្មានកូវីដ-១៩, ៣). លទ្ធភាពនៃការកើតឡើងនូវវីរុសបំប្លែងខ្លួនប្រភេទថ្មី, ៤). ការបន្តបន្ទុចបង្អាក់កាន់តែខ្លាំងនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល, ៥). ការកើនឡើងសម្ពាធអតិផរណាជាងការរំពឹងទុក, ៦). ការកើនឡើងនូវភាពតានតឹងផ្នែកហិរញ្ញវត្ថុ, និង ៧). ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ជាដើម ។ ក្នុងបរិបទនេះ, ការចែកចាយ និងការចាក់វ៉ាក់សាំងកូវីដ-១៩ឱ្យបានទូលំទូលាយ, ការរក្សាតុល្យភាពរវាងគោលនយោបាយសង្គម និងគោលនយោបាយសេដ្ឋកិច្ច, និងការរក្សាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ នឹងដើរតួនាទីកាន់តែសំខាន់ក្នុងការស្តារ និងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញ ។

**១៤.** ស្របគ្នានឹងការព្យាករសេដ្ឋកិច្ចសកលឡើងវិញ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើង ក្នុងអត្រា ៥,៤% ក្នុងឆ្នាំ ២០២២ ដែលបន្តគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការសកល បើទោះបីជារងការប៉ះទង្គិចពីការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី ។ ការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន បានបង្កផលប៉ះពាល់ដោយប្រយោលដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការកើនឡើងថ្លៃទំនិញគ្រប់ប្រភេទ ជាពិសេស ប្រេងឥន្ធនៈ និងវត្ថុធាតុដើមកសិកម្ម រួមមាន ជី និងថ្នាំសម្លាប់សត្វល្អិត ជាដើម ។ ទន្ទឹមនេះ, ការកើនឡើងថ្លៃជារួម បានបង្កផលប៉ះពាល់ដល់សកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជន ។ យ៉ាងណាមិញ, ផលប៉ះពាល់នៃសង្គ្រាមនេះមកលើសេដ្ឋកិច្ចកម្ពុជាមានទំហំតូចប៉ុណ្ណោះ ដោយហេតុថាទំនាក់ទំនងសេដ្ឋកិច្ចដោយផ្ទាល់រវាងកម្ពុជាជាមួយនឹងប្រទេសជម្លោះទាំងពីរមានកម្រិតទាប ។ ផលប៉ះពាល់នេះត្រូវបានប៉ះប៉ូវមកវិញមួយផ្នែកធំ តាមរយៈការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ និងការបើកប្រទេសឡើងវិញ ដែលបានអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពវិញ ។ រាជរដ្ឋាភិបាលក៏បាននិងកំពុងបន្តអនុវត្តវិធានការអន្តរាគមន៍ រួមមាន ការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ, កម្មវិធីសាច់ប្រាក់ពលកម្ម និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងអំឡុងពេលព្យួរការងារ ជាដើម ដែលបានចូលរួមចំណែកទ្រទ្រង់ជីវភាពប្រជាជន និង

សកម្មភាពអាជីវកម្ម និងចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចជារួម សម្រាប់ឆ្នាំ ២០២២ ។ សម្រាប់ឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើន ក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកនៃការបន្តនិន្នាការល្អប្រសើរនៃតម្រូវការសកល និងទំនុកចិត្តវិនិយោគ ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត និងអាចគ្រប់គ្រងបាន ។ ទន្ទឹមនេះ, **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** នឹងបន្តចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងការបង្កើនតម្លៃបន្ថែមទៀតដល់អនុវិស័យជំរុញកំណើនដែលមានស្រាប់ ក៏ដូចជាលើកកម្ពស់អនុវិស័យសក្តានុពល ដែលជាចន្ទល់កំណើនថ្មី រួមមាន អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យគមនាគមន៍ ព្រមទាំងការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម ។ ស្របជាមួយគ្នានេះដែរ, រាជរដ្ឋាភិបាលបានគិតគូរក្នុងការបង្កើនកញ្ចប់អន្តរាគមន៍ ជាពិសេសផ្នែកសង្គម និងសេដ្ឋកិច្ច ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងអតិផរណា និងការបង្កើនការវិនិយោគក្នុងស្រុកក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតការងារជូនប្រជាជនផងដែរ ។ ជារួម, សេដ្ឋកិច្ចកម្ពុជាមានសក្តានុពលខ្ពស់ ក្នុងការសម្រេចបាននូវកំណើនរឹងមាំប្រកបដោយចីរភាព ក្នុងរយៈពេលមធ្យមខាងមុខ ដោយសារការកែសម្រួលឡើងវិញជាយុទ្ធសាស្ត្រនូវខ្សែច្រវាក់ផ្គត់ផ្គង់ និងតម្លៃតំបន់ និងសកល តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម (Reshoring and Relocation) សំដៅធានានិរន្តរភាពនៃខ្សែច្រវាក់ផលិតកម្ម ដែលបាននិងកំពុងផ្តល់នូវឱកាសសម្រាប់តំបន់អាស៊ាន រួមទាំង កម្ពុជា ក្នុងការទទួលបានវិនិយោគបន្ថែម ដើម្បីទ្រទ្រង់កំណើនផងដែរ ។ បន្ថែមលើនេះ, ការចាប់ផ្តើមអនុវត្តនូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាក៏នឹងជួយធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងជំរុញដល់ការទាក់ទាញវិនិយោគបន្ថែម ជាពិសេស សម្រាប់ឧស្សាហកម្មដែលបម្រើដល់ការនាំចេញ ។ ផ្អែកលើសម្មតិកម្មខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ និង ២០២៣ ត្រូវបានព្យាករដូចខាងក្រោម ÷

**១៥.** ***វិស័យកសិកម្ម*** ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនក្នុងរង្វង់ ០,៧% ក្នុងឆ្នាំ ២០២២ និង ១,១% ក្នុងឆ្នាំ ២០២៣ ដោយសារកំណើនរឹងមាំនៃអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យដំណាំ ស្របពេលដែលអនុវិស័យនេសាទរំពឹងថានឹងបន្តងើបឡើងវិញសន្សឹមៗ ។ ជាមួយគ្នានេះ, ការដាក់ចេញនូវ **គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០** នឹងជួយជំរុញកំណើនជារួម តាមរយៈការធ្វើទំនើបកម្មកសិកម្មកម្ពុជាឱ្យកាន់តែមានភាពប្រកួតប្រជែង, បរិយាប័ន្ន និងធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

**១៦.** អនុវិស័យដំណាំ ត្រូវបានព្យាករថានឹងមានកំណើន ១,៤% ក្នុងឆ្នាំ ២០២២ និង ១,៦% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវកំណើននៃការនាំចេញផលិតផលកសិកម្ម ជាពិសេស ដំណាំរួមផ្សំ និងឧស្សាហកម្ម ដែលនឹងបន្តជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមាន “កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន”, “កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ” និង “កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ

តំបន់" ជាដើម គួបផ្សំនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការនាំចូលវត្ថុធាតុដើមកសិកម្ម និងការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក ។

**១៧.** អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានៅនឹងបន្តរក្សាបានកំណើនល្អប្រសើរ ក្នុងរង្វង់ ១,០% ដូចគ្នា សម្រាប់ឆ្នាំ ២០២២ និង ២០២៣ ដោយសារការរំពឹងទុកនូវកំណើនផលិតកម្មចិញ្ចឹមសត្វ ជាពិសេស ផលិតកម្មជ្រូក ដើម្បីឆ្លើយតបទៅនឹងការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា ។

**១៨.** អនុវិស័យនេសាទ ត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះ ក្នុងអត្រា -០,៥% ក្នុងឆ្នាំ ២០២២ ដោយសារបញ្ហាប្រឈមជារចនាសម្ព័ន្ធក្នុងទីផ្សារផ្គត់ផ្គង់ត្រី ដែលបានធ្វើឱ្យកសិដ្ឋានចិញ្ចឹមត្រីកាត់បន្ថយផលិតកម្ម និងខ្លះទៀតសម្រេចចិត្តបោះបង់ចោលការចិញ្ចឹមទាំងស្រុង ។ ក្នុងឆ្នាំ ២០២៣, អនុវិស័យនេះត្រូវបានព្យាករថានឹងងើបឡើងវិញ ក្នុងអត្រា ០,៦% ក្រោមការរំពឹងទុកនូវការកើនឡើងសន្សឹមៗនៃផលចាប់ទឹកសាប និងផលិតកម្មវារីវប្បកម្ម ដោយសារ ការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព ។

**១៩.** ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មជារួម នៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ រួមមានកំណើនទាបនៃផលិតភាពដី និងផលិតភាពពលកម្ម, ថ្លៃដើមផលិតកម្មខ្ពស់, ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ភាពទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម, និងកង្វះការវិនិយោគលើការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពលដើម្បីទាញយកតម្លៃបន្ថែម ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ និងជំរុញវិស័យកសិកម្មឱ្យមានកំណើនកាន់តែល្អប្រសើរ សំដៅគាំទ្រសេដ្ឋកិច្ចជាតិ ព្រមទាំងលើកកម្ពស់សន្តិសុខស្បៀង, រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តវិធានការគោលនយោបាយ ដូចជា៖ ១). ការវិនិយោគលើផលិតកម្មពូជសុទ្ធដែលមានគុណភាពល្អ, ២). ការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតតូច និងមធ្យម ក្នុងតំបន់ដែលមានសក្តានុពលស្រូវក្រអូប និងដំណាំឧស្សាហកម្មផ្សេងទៀត, ៣). ការលើកកម្ពស់ការកែច្នៃធាតុចូលកសិកម្ម ដូចជា ចំណីសត្វ ជីគីមី និងថ្នាំកសិកម្មក្នុងស្រុក, ៤). ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាពិសេស ផ្សារបោះដុំកសិផល, មន្ទីរពិសោធន៍, បន្ទប់ត្រជាក់សម្រាប់ស្តុកទុកកសិផល ជាដើម, ៥). ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលស្របនឹងតម្រូវការទីផ្សារ, ៦). ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាព (Quality Infrastructure System) ដើម្បីឆ្លើយតបទៅនឹងតម្រូវការស្តង់ដារសម្រាប់ការនាំចេញ, ៧). ការជំរុញការបង្កើតឧទ្យានកសិ-ឧស្សាហកម្ម (Agro-Industrial Park), ៨). ការស្រាវជ្រាវ និងអភិវឌ្ឍន៍, ៩). ការជំរុញការអនុវត្តកិច្ចសន្យាកសិកម្ម (Contract Farming) ឱ្យកាន់តែទូលំទូលាយ, ១០). ការតភ្ជាប់កសិករ និងសហគមន៍កសិកម្មទៅកាន់ទីផ្សារ, ១១). ការពង្រឹងការអនុវត្តច្បាប់លើការត្រួតពិនិត្យគុណភាពធាតុចូលកសិកម្ម, និង ១២). ការសម្របសម្រួលស្ថាប័ន ។

**២០.** ***វិស័យឧស្សាហកម្ម*** ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើង ក្នុងអត្រា ៩,០% ក្នុងឆ្នាំ ២០២២ និង ៩,២% ក្នុងឆ្នាំ ២០២៣ ដែលកំពុងត្រឡប់មកនិន្នាការកំណើនមុនពេលវិបត្តិជំងឺកូវីដ-១៩ ។ ការវិលត្រឡប់ទៅរកវិថីកំណើននេះ គាំទ្រដោយការរំពឹងទុកការបន្តភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ដែលនឹងបន្តជំរុញកំណើននៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ។ យ៉ាងណាមិញ, អនុវិស័យសំណង់ត្រូវបានរំពឹងថានឹងបន្តងើបឡើងក្នុងល្បឿនយឺត ដោយសារការរំពឹងទុកការបន្តងើបឡើងវិញសន្សឹមៗនៃលំហូរទុនវិនិយោគ ។

**២១.** អនុវិស័យកាត់ដេរ ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនរឹងមាំ ក្នុងអត្រា ១០,៨% ក្នុងឆ្នាំ ២០២២ និង ៨,១% ក្នុងឆ្នាំ ២០២៣ គាំទ្រដោយស្ថិរភាពនៃកត្តាក្នុងស្រុក ដែលសម្រេចបានតាមរយៈអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ខ្ពស់របស់កម្មករ-និយោជិត, ភាពល្អប្រសើរនៃកត្តាខាងក្រៅ ជាពិសេស ការរំពឹងទុកនូវការបន្តកើនឡើងតម្រូវការពីទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងការបន្តទទួលបានការបង្វែរការបញ្ជាទិញពីប្រទេសក្នុងតំបន់ ជាពិសេស ប្រទេសមីយ៉ាន់ម៉ា ។ ដោយឡែក, អនុវិស័យកាត់ដេរក៏បន្តប្រឈមនឹងបញ្ហាមួយចំនួន រួមមានជាអាទិ៍ ការកើនឡើងនូវការប្រកួតប្រជែងពីប្រទេសជិតខាង, ការបាត់បង់នូវការបង្វែរការបញ្ជាទិញ, ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធ និងភាពមានកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងផលិតកម្មជាដើម ។ ជាការឆ្លើយតប, រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧** ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ក៏ដូចជាលើកកម្ពស់ភាពប្រកួតប្រជែងក្នុងអនុវិស័យនេះ ។

**២២.** អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនល្អប្រសើរក្នុងរង្វង់ ១២,២% ក្នុងឆ្នាំ ២០២២ និង ១៣,៣% ក្នុងឆ្នាំ ២០២៣ ។ កំណើនរឹងមាំនេះ គាំទ្រដោយការរំពឹងទុកភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ជាពិសេសទីផ្សារសហរដ្ឋអាមេរិក ស្របជាមួយនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមាន **កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ,** ព្រមទាំងការអនុវត្ត **ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា** ។ ទោះជាយ៉ាងនេះក្តី, បញ្ហាជារចនាសម្ព័ន្ធមួយចំនួន បាននិងកំពុងរាំងស្ទះដល់ការរីកចម្រើននៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ រួមមាន បញ្ហាកង្វះវត្ថុធាតុដើមក្នុងស្រុក, កង្វះកម្លាំងពលកម្មជំនាញបច្ចេកទេស, ថ្លៃអគ្គិសនីខ្ពស់, កង្វះប្រភេទអាជីវកម្មធុនតូច និងមធ្យម (Missing Middle), និងភាពមានកម្រិតក្នុងការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងតំបន់ ។ ក្នុងន័យជំរុញអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរឱ្យដល់សក្តានុពល និងក្លាយជាវិស័យចន្ទល់កំណើនថ្មី, រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការមុតស្រួច ដែលបានដាក់ចេញតាមរយៈយន្តការគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ដើម្បីសម្របសម្រួល និងដោះស្រាយ បញ្ហាជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗ ដែលមានចរិតអន្តរស្ថាប័ន សំដៅលើកកម្ពស់ផលិតកម្មក្នុងស្រុក ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ និងពន្លឿនការដាក់ចេញ **ផែនការមេអភិវឌ្ឍន៍វិស័យថាមពល ២០២០-២០៤០** សំដៅធានាឱ្យបាននូវការផ្គត់ផ្គង់

ថាមពលគ្រប់គ្រាន់ ឆ្លើយតបនឹងការកើនឡើងនៃតម្រូវការប្រើប្រាស់, និងបង្កើនភាពប្រកួតប្រជែង តាមរយៈការកាត់បន្ថយថ្លៃដើម និងការបង្កើនប្រសិទ្ធភាពថាមពល ដោយការកាត់បន្ថយកំហាតថាមពល ។

**២៣.** អនុវិស័យសំណង់ ត្រូវបានព្យាករថានឹងបន្តងើបឡើងវិញក្នុងល្បឿនយឺត ក្នុងអត្រា ៣,០% ក្នុងឆ្នាំ ២០២២ និង ៧,២% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃវំហូរវិនិយោគទុនពីបរទេស សម្រាប់សំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ខណៈសំណង់លំនៅឋានថ្លៃទាប និងមធ្យម រំពឹងថានៅបន្តរក្សាកំណើនល្អប្រសើរ ដោយសារការកើនឡើងនៃតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំគ្រួសារស្របគ្នាទៅនឹងនិន្នាការនៃការកើនឡើងការវិនិយោគក្នុងស្រុក ។ យ៉ាងណាមិញ, ការបន្តកើនឡើងខ្ពស់នៃឥណទានផ្តល់ទៅវិស័យសំណង់ក្នុងស្រុក គឺជាហានិភ័យមួយសម្រាប់អនុវិស័យនេះ និងវិស័យហិរញ្ញវត្ថុទាំងមូលផងដែរ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តតាមដានដោយយកចិត្តទុកដាក់លើការវិវត្តនៃអនុវិស័យនេះ ដើម្បីដាក់ចេញគោលនយោបាយអន្តរាគមន៍បានទាន់ពេលវេលា សំដៅបញ្ចៀសហានិភ័យដែលអាចកើតមានឡើង ។

**២៤.** ***វិស័យសេវាកម្ម*** ត្រូវបានព្យាករថានឹងងើបឡើងវិញជាសន្សឹមៗ ក្នុងអត្រា ៤,៣% ក្នុងឆ្នាំ ២០២២ និង ៦,៦% ក្នុងឆ្នាំ ២០២៣ ដោយសារការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងការបន្តនិន្នាការកើនឡើងនៃអនុវិស័យគាំទ្រផ្សេងទៀត រួមមាន អនុវិស័យលក់ដុំ-រាយ, អនុវិស័យអចលនទ្រព្យ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ។

**២៥.** អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានព្យាករថានឹងងើបឡើងវិញ ក្នុងអត្រា ១៦,៥% ក្នុងឆ្នាំ ២០២២ និង ២៣,៤% ក្នុងឆ្នាំ ២០២៣ បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកពីរឆ្នាំជាប់គ្នា ដោយសារការរំពឹងទុកការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ ប៉ុន្តែក្នុងល្បឿនយឺត ខណៈចំនួនភ្ញៀវទេសចរជាតិ ត្រូវបានរំពឹងថានឹងងើបឡើងវិញលឿនជាង ដោយសារការបង្កើតបាននូវភាពសុំាសហគមន៍ ដែលបានអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច ដំណើរការឡើងវិញ និងត្រឡប់ទៅរកនិន្នាការធម្មតាក្នុងគន្លងប្រក្រតីភាពថ្មី ។ ទោះជាយ៉ាងនេះក្តី, វិស័យទេសចរណ៍ ជាវិស័យងាយរងគ្រោះ និងប្រឈមហានិភ័យខ្ពស់ ។ ទន្ទឹមនឹងការកើនឡើងនូវការប្រកួតប្រជែង ក្នុងតំបន់, វិស័យនេះក៏ប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន រួមមាន ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សមត្ថភាពស្ថាប័ន និងការធ្វើពិពិធកម្មគោលដៅ, ផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការបាត់បង់តម្លៃបន្ថែមសេដ្ឋកិច្ច ដោយសារភាពមានកម្រិតនៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ ។ ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើការជំរុញទេសចរណ៍ជាតិ តាមរយៈការជំរុញការអនុវត្ត **វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ ២០២១-២០២៣** និង ជាពិសេស **ផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** ដើម្បីបង្កើនការស្តារទំនុកចិត្តសម្រាប់ទេសចរ, បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា, បង្កើតប្រភេទតម្រូវការថ្មីៗ, កសាងសមត្ថភាព ដើម្បីគាំទ្រតម្រូវការនាពេលអនាគត និងជំរុញការធ្វើបរិវត្តកម្ម (Transformation) ក្នុងវិស័យទេសចរណ៍ ។

**២៦.** អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើន ៤,៣% ក្នុងឆ្នាំ ២០២២ និង ៦,៧% ក្នុងឆ្នាំ ២០២៣ ដោយសារការងើបឡើងវិញជាបណ្តើរៗនៃអនុវិស័យដែលជាប្រភពចំណូលរបស់ប្រជាជន ។

ទោះជាយ៉ាងនេះក្តី, អនុវិស័យនេះប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ រួមមាន ការវិវត្តនៃវីរុសបំប្លែងខ្លួនថ្មី និងការបន្តកើនឡើងថ្លៃ ដែលអាចបន្តដាក់សម្ពាធដល់អាជីវកម្មក្នុងស្រុក និងប៉ះពាល់ដល់សកម្មភាពប្រើប្រាស់ក្នុងស្រុក ។ ទន្ទឹមនេះ, អាជីវកម្មបែបប្រពៃណី (Brick-And-Mortar) ក្នុងអនុវិស័យលក់ដុំ-រាយ ក៏បាននិងកំពុងប្រឈមបញ្ហាក្នុងការសម្របខ្លួនជាមួយនឹងការកើនឡើងនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងបរិបទនៃបរិវត្តកម្មឌីជីថលសង្គម-សេដ្ឋកិច្ច (Digital Transformation) ។ ជាការឆ្លើយតប រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់ជំរុញការអនុវត្តយន្តការ និងគំនិតផ្តួចផ្តើមនានា រួមមាន **មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ, ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា** និង **សាជីវកម្មធានាឥណទានកម្ពុជា** ក្នុងគោលបំណងផ្តល់ការគាំទ្រ ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់អាជីវកម្មដែលជួបប្រទះបញ្ហា សំដៅជំរុញឌីជីថលូបនីយកម្ម (Digitalization) ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម ។

**២៧.** អនុវិស័យអចលនទ្រព្យ ត្រូវបានព្យាករថានឹងបន្តងើបឡើងវិញក្នុងអត្រាកំណើនទាប ក្នុងអត្រា ២,៥% ក្នុងឆ្នាំ ២០២២ និង ៥,២% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃសកម្មភាពទិញ-លក់ និងជួលអចលនទ្រព្យថ្លៃខ្ពស់ រួមមាន ខុនដូ និងអាផាតមិន ស្របពេលដែលការវិនិយោគ និងតម្រូវការក្នុងស្រុកលើអចលនទ្រព្យផ្នែកលំនៅឋានថ្លៃទាប និងមធ្យម រំពឹងថានៅបន្តរក្សាកំណើនល្អ ។ ទោះជាយ៉ាងនេះក្តី, អនុវិស័យនេះនៅតែប្រឈមនឹងហានិភ័យខ្ពស់ស្រដៀងគ្នាទៅនឹងអនុវិស័យសំណង់ ដោយហេតុថាអនុវិស័យអចលនទ្រព្យមានទំនាក់ទំនងខ្ពស់ជាមួយនឹងវិស័យហិរញ្ញវត្ថុក្នុងនិងក្រៅប្រព័ន្ធធនាគារ (កម្ចីផ្តល់ដោយក្រុមហ៊ុនអភិវឌ្ឍន៍) ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់លើការវិវត្តនៃអនុវិស័យនេះ ជាមួយនឹងការដាក់ចេញនូវវិធានការអន្តរាគមន៍ផ្សេងៗ សំដៅបញ្ចៀសហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុ ។

**២៨.** អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៦,១% ក្នុងឆ្នាំ ២០២២ និង ៧,១% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពដឹកជញ្ជូន ខណៈការប្រើប្រាស់ប្រព័ន្ធឌីជីថលមានការកើនឡើង ស្របទៅនឹងនិន្នាការនៃការផ្លាស់ប្តូរឥរិយាបថរស់នៅរបស់ប្រជាជន និងសកម្មភាពអាជីវកម្មក្នុងគន្លងប្រក្រតីភាពថ្មី ។ ទោះជាយ៉ាងនេះក្តី អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ក៏បន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមាន ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក ខណៈ ថ្លៃសេវាអ៊ីនធឺណិតនៅមានកម្រិតខ្ពស់ ធៀបនឹងប្រទេសក្នុងតំបន់ ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ, រាជរដ្ឋាភិបាលនឹងបន្តជំរុញការរៀបចំតំបន់ត្រួតពិនិត្យរួមគ្នានៅតាមច្រកទ្វារព្រំដែន ដើម្បីសម្រួលចរាចរណ៍ទំនិញ និងមនុស្ស, ជំរុញការងារអភិវឌ្ឍន៍ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ និងបង្កើនល្បឿននីតិវិធី ដើម្បីកាត់បន្ថយឯកសារ និងចំណាយដឹកជញ្ជូន, បន្តពង្រីកសមត្ថភាពផ្ទុកកុងតឺន័រនៅទីលានចំណតផែ, បន្តពង្រីក និងធ្វើទំនើបកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដើម្បីលុបបំបាត់ឧបសគ្គជម្រៅទឹកដល់ការចតនាវា, និងជាពិសេស ជំរុញការអនុវត្តនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដោយបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងលើកកម្ពស់ការចាប់យកឌីជីថលនៅកម្ពុជា ។

**តារាងទី ១÷ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| កំណើន (%) | ២០២១ | ២០២២ ប៉ាន់. | ២០២៣ ព្យា. |
|---|---|---|---|
| **កំណើន ផសស** | **៣,០%** | **៥,៤%** | **៦,៦%** |
| **វិស័យកសិកម្ម** | **១,១%** | **០,៧%** | **១,១%** |
| ដំណាំ | ២,៦% | ១,៤% | ១,៦% |
| នេសាទ | -២,៤% | -០,៥% | ០,៦% |
| ការចិញ្ចឹមសត្វ | ២,២% | ១,០% | ១,០% |
| ព្រៃឈើ | -០,៨% | -១,៥% | -១,៤% |
| **វិស័យឧស្សាហកម្ម** | **៨,៦%** | **៩,០%** | **៩,២%** |
| កាត់ដេរ | ១០,៨% | ១០,៨% | ៨,១% |
| សំណង់ | ១,១% | ៣,០% | ៧,២% |
| កម្មន្តសាលមិនមែនកាត់ដេរ | ១៣,៩% | ១២,២% | ១៣,៣% |
| **វិស័យសេវាកម្ម** | **-១,៩%** | **៤,៣%** | **៦,៦%** |
| សណ្ឋាគារនិងភោជនីយដ្ឋាន | -៣៩,៥% | ១៦,៥% | ២៣,៤% |
| លក់ដុំ-រាយ | ១,៦% | ៤,៣% | ៦,៧% |
| អចលនទ្រព្យ | ០,៥% | ២,៥% | ៥,២% |
| ដឹកជញ្ជូននិងគមនាគមន៍ | ២,៨% | ៦,១% | ៧,១% |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (២០២១) និងការប៉ាន់ស្មាន និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែឧសភា ឆ្នាំ ២០២២

**២៩.** ជាមួយគ្នានេះ ក្នុងឆ្នាំ ២០២២, អតិផរណាត្រូវបានប៉ាន់ស្មានថានឹងអាចកើនឡើង ក្នុងរង្វង់ ៥,០% ដោយសារការកើនឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត បណ្ដាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ។ យ៉ាងណាមិញ ក្នុងឆ្នាំ ២០២៣, អតិផរណាត្រូវបានរំពឹងថានឹងថមថយមកវិញ ក្នុងរង្វង់ ២,៥% ដោយសារការរំពឹងទុកការវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេង និងទំនិញផ្សេងៗទៀត ក៏ដូចជាសកម្មភាពសេដ្ឋកិច្ច ។ អត្រាប្តូរប្រាក់រំពឹងថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រចាំឆ្នាំ ប្រមាណ **៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល ។

**៣០. និទនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងរួមតូចមកវិញ ក្នុងទំហំប្រមាណ ២៦,៨% នៃ ផសស ក្នុងឆ្នាំ ២០២២ ធៀបនឹង ៤៥,៤% នៃ ផសស ឆ្នាំ ២០២១ ក្រោមការរំពឹងទុកការត្រឡប់ទៅរកប្រក្រតីភាពនៃសមតុល្យពាណិជ្ជកម្ម ខណៈដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បញ្ញើពីក្រៅប្រទេស (remittance) ក៏ត្រូវបានរំពឹងថានឹងងើបឡើងវិញសន្សឹមៗ ស្របតាមភាពស្រាកស្រាន្តនៃស្ថានភាព

នៃវិបត្តិជំងឺកូវីដ-១៩ជាបណ្ដើរៗ ។ សម្រាប់ឆ្នាំ ២០២៣, ឱនភាពគណនីចរន្តរំពឹងថានឹងបន្ថយមកតូច ក្នុងរង្វង់ប្រមាណ ១៤,១% នៃ ផសស ដោយសារការរំពឹងទុកការបន្តកើនឡើងនៃការនាំចេញ និងការបន្តនិន្នាការងើបឡើងនៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ ។ ជាមួយគ្នានេះ, វិហ្វរវិនិយោគផ្ទាល់ពីបរទេស សម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងងើបឡើងក្នុងរង្វង់ ១២,០% នៃ ផសស និង ១១,៦% នៃ ផសស រៀងគ្នា ដោយសារការបន្តកើនឡើងនូវទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែអំណោយផលរបស់កម្ពុជា ក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននូវខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់ តំបន់ និងសកល ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត ។ ជាលទ្ធផល, **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២១ ២៧១ និង ២២ ១៥៥ លានដុល្លារអាមេរិក ដែលធានាការនាំចូលបានប្រមាណ ៧,៧ និង ៧,៦ ខែ ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣ រៀងគ្នា ។

**តារាងទី ២៖ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០២១ | ២០២២ ប៉ាន់. | ២០២៣ ព្យា. |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១៩ ៤៦៩ | ២៣ ៤១៨ | ២៧ ៣៤៩ |
| ការនាំចូល (លានដុល្លារអាមេរិក) | ៣០ ៧២៦ | ៣០ ៩៤០ | ៣២ ៥៤៦ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ១២ ៣៣៩ | ៧ ៩២៩ | ៤ ៥៥៦ |
| វិហ្វរទុនវិនិយោគបរទេស (លានដុល្លារអាមេរិក) | ៣ ៤៨៦ | ៣ ៥៥៧ | ៣ ៧៤៥ |
| ការនាំចេញ (ភាគរយនៃ ផសស) | ៧១,៧% | ៧៩,១% | ៨៤,៧% |
| ការនាំចូល (ភាគរយនៃ ផសស) | ១១៣,១% | ១០៤,៧% | ១០០,៨% |
| ឱនភាពសមតុល្យពាណិជ្ជកម្មសរុប (ភាគរយនៃ ផសស) | ៤១,៤% | ២៥,៦% | ១៦,១% |
| ឱនភាពគណនីចរន្ត (ភាគរយនៃ ផសស) | ៤៥,៤% | ២៦,៨% | ១៤,១% |
| វិហ្វរទុនវិនិយោគបរទេស (ភាគរយនៃ ផសស) | ១២,៨% | ១២,០% | ១១,៦% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០២១) និងការប៉ាន់ស្មាន និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែឧសភា ឆ្នាំ ២០២២

**៣១.** ទោះជាយ៉ាងនេះក្តី, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាបាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជា ដែលជាកត្តាខាងក្រៅមួយចំនួន រួមមាន៖

១). ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ ជាពិសេសការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលអាចមានលទ្ធភាពបង្កឱ្យមានវិបត្តិខ្វះស្បៀង និងថាមពល,

២). ការថមថយសេដ្ឋកិច្ចចិន,

៣). ការរឹតបន្តឹងលឿនជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសអភិវឌ្ឍន៍,

៤). ភាពមិនប្រាកដប្រជានៃការបំប្លែងខ្លួនប្រភេទថ្មីនៃជំងឺកូវីដ-១៩,

៥). ការរអាក់រអួលកាន់តែខ្លាំងនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល,

៦). ការកើតមានវិបត្តិហិរញ្ញវត្ថុក្រោយពេលវិបត្តិជំងឺកូវីដ-១៩ បានបញ្ចប់, និង

៧). ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។

**៣២.** ទន្ទឹមនឹងការកើនឡើងនៃហានិភ័យខាងក្រៅ កម្ពុជានៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធខាងក្នុងមួយចំនួន ដែលធ្វើឱ្យការធ្វើពិពិធកម្មសេដ្ឋកិច្ចមានល្បឿនយឺត និងភាពប្រកួតប្រជែងមានកម្រិត,រួមមាន÷

១). ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់,

២). ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច,

៣). បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ,

៤). ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និង

៥). ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ។

**៣៣.** ក្នុងបរិបទនេះ, ដើម្បីឆ្លើយតបនឹងនិន្នាការថ្មីៗ ក៏ដូចជាគ្រប់គ្រងហានិភ័យដែលអាចកើតមាន, រាជរដ្ឋាភិបាលបាននិងកំពុងដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា តាមរយៈការដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ,គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយជារចនាសម្ព័ន្ធ ដើម្បីសម្រេចឱ្យបាននូវការរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច ។ ចំពោះមុខ, រាជរដ្ឋាភិបាលបានដាក់ចេញ និងបន្តជំរុញការអនុវត្ត **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ក្នុងគោលបំណងស្តារ និងពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចឱ្យរស់រវើក និងត្រឡប់ទៅកំណើនសក្តានុពល ប្រកបដោយចីរភាព និងបរិយាប័ន្ន, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និងសកល និងកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច ។ **ជាមួយគ្នានេះ ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងជំរុញពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើអាទិភាពចំនួន ៤ រួមមាន÷**

- **បន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋឱ្យខាងតែបាន ដោយផ្តោតលើការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំ និងប្រសិទ្ធភាពនៃស្ថាប័នរដ្ឋ, ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបាននូវរដ្ឋបាលសាធារណៈស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ។
- **បន្តជំរុញការកសាងភាពធន់នៃសេដ្ឋកិច្ច** តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់ភាពប្រកួតប្រជែង ដោយផ្តោតលើការចាប់យកដៃគូពាណិជ្ជកម្មក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី, ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម, ការជំរុញឌីជីថលូបនីយកម្មសង្គម-សេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជន, ជាពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឡូជីស្ទីក, ថាមពល, បៃតង និងឌីជីថល ប្រកបដោយគុណភាពខ្ពស់ ។

- **ពន្លឿនការកសាងភាពធន់នៃសង្គម** តាមរយៈការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ទាំងគុណភាព និងវិសាលភាព ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិ ឬហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុនាពេលអនាគត ព្រមទាំងការបន្តអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតលើការពង្រឹងគុណភាពនៃវិស័យអប់រំ និងជំនាញបច្ចេកទេស ។
- **ជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ** តាមរយៈការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសមត្ថភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព រឹងមាំធន់នឹងវិបត្តិ និងប្រកបដោយបរិយាប័ន្ន សំដៅគាំទ្រសកម្មភាពសេដ្ឋកិច្ចទាំងមូល និងការសម្របខ្លួន និងការឆ្លើយតបទៅនឹងការប្រែប្រួលនៃសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ និងសកល និង តាមរយៈការបន្តពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើការធ្វើទំនើបកម្ម និងវិចារណកម្មប្រព័ន្ធគ្រប់គ្រងចំណាយថវិកា និងគ្រប់គ្រងបំណុលសាធារណៈឱ្យមានប្រសិទ្ធភាព និងចីរភាព ព្រមទាំងការបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធឆ្លើយតបនឹងវិបត្តិរបស់ធនាគារ ជាដើម ។

**៤. ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

**៣៤.** ដើម្បីធានាការសម្រេចបាននូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ស្របតាមទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣**, ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ កំណត់យកអាទិភាពសំខាន់ៗដូចខាងក្រោម÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន,
- បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកកំណើនសក្តានុពល តាមរយៈការជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣,
- ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា ដែលអាចឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតមានជាយថាហេតុ,
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញ ប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ,

- គិតគូរដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ,
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធ,
- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព, និង
- បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្ត ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច ។

**៣៥.** ផ្អែកលើមូលដ្ឋានក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលដាក់ចេញនូវ **"គោលនយោបាយវិត្តរកម្មថវិកាចំគោលដៅ ដោយឈរលើគោលការណ៍ប្រសិទ្ធភាពថវិកា"** នៅក្នុងឆ្នាំ ២០២៣ ដែលជាឆ្នាំចុងអាណត្តិ សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ និងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា ព្រមទាំងគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ច ស្របតាមទិសដៅជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុង **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលនឹងបន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍សង្គម-សេដ្ឋកិច្ច ដើម្បីដោះស្រាយផលប៉ះពាល់ ដែលនៅបន្តអូសបន្លាយពីវិបត្តិជំងឺកូវីដ-១៩, លើកកម្ពស់សុខុមាលភាពសង្គម, បង្កើតការងារជូនប្រជាពលរដ្ឋ, ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ពន្លឿនការចាប់យកឌីជីថលនៅកម្ពុជា ព្រមទាំងជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង ។

**៣៦.** ចំណូលក្នុងស្រុក ឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងបន្តងើបឡើងវិញ ដោយផ្អែកសំខាន់ទៅលើការបន្តកំណើនវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា ជាពិសេស ការអនុវត្តគោលនយោបាយគាំទ្រនានា របស់រាជរដ្ឋាភិបាល ដែលនឹងជួយជំរុញបន្ថែមទៀតនូវសកម្មភាពធុរកិច្ច និងពាណិជ្ជកម្មក្នុងស្រុកឱ្យកាន់តែមានភាពរស់រវើកឡើងវិញ ខណៈវិបត្តិជំងឺកូវីដ-១៩ កាន់តែមានភាពស្រាកស្រាន្ត ។ ក្នុងនោះ, ចំណូលសារពើពន្ធ ត្រូវបានរំពឹងថានឹងបន្តមានកំណើនល្អ ស្របតាមការបន្តរីកធំនៃមូលដ្ឋានពន្ធ តាមរយៈការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ និងការលើកកម្ពស់វប្បធម៌អនុលោមភាពអ្នកជាប់ពន្ធ ព្រមទាំងភាពល្អប្រសើរនៃសកម្មភាពប្រើប្រាស់, ផលិតកម្មក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ ។ ដោយឡែក, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថានឹងបន្តងើបឡើងវិញ ស្របតាមស្ថានភាពនៃវិស័យទេសចរណ៍ ខណៈរាជរដ្ឋាភិបាលបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពលនានា ។

**៣៧.** ទោះជាយ៉ាងនេះក្តី, ការប្រមូលចំណូល អាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមាន÷ (១). ភាពមិនប្រាកដប្រជា កើតចេញពីការវិវត្តកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយសកល ដែលអាចនាំមកនូវផលប៉ះទង្គិចដល់សេដ្ឋកិច្ចកម្ពុជា ដែលជាហេតុធ្វើឱ្យចំណូលប្រឈមនឹងកំណើនយឺត ក្នុងរយៈពេលមធ្យមខាងមុខ, (២). មូលដ្ឋានយកពន្ធ និងអនុលោមភាពអ្នកបង់ពន្ធនៅមានកម្រិត, និង (៣). ភាពមានកម្រិតនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ដោយសារកង្វះខាតនៃបទប្បញ្ញត្តិគោល និងលិខិតបទដ្ឋានគតិយុត្តគាំទ្រ, បញ្ហាអភិបាលកិច្ច និងភាពមានកម្រិតនៃប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រង ជាដើម ។

**៣៨.** ក្របខណ្ឌចំណាយសាធារណៈឆ្នាំ ២០២៣ ត្រូវបានរៀបចំឡើង ក្នុងបរិបទនៃការស្តារ និងការរៀបចំមូលដ្ឋានសង្គម-សេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីបានទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងស្របពេលដែលឆ្នាំ ២០២៣ គឺជាឆ្នាំចុងអាណត្តិ ដែលរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពកាន់តែខ្ពស់ចំពោះចំណាយលើផ្នែកសង្គម ។ ជាមួយគ្នានេះ, ជាទិសដៅគោលនយោបាយ ចំណាយសាធារណៈឆ្នាំ ២០២៣ នឹងផ្តល់អាទិភាពខ្ពស់ទៅលើ÷

(១). ការបន្តគាំពារ និងលើកកម្ពស់ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយយក **មនុស្សជាអាទិភាពទី ១** ព្រមទាំងរៀបចំមូលដ្ឋានសង្គមកម្ពុជាឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពង្រឹងគុណភាព និងការពង្រីកវិសាលភាពនៃវិស័យសុខាភិបាល និងប្រព័ន្ធគាំពារសង្គម;

(២). ការបន្តស្តារ និងពង្រឹងមូលដ្ឋានអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩, ជាពិសេស ជំរុញវិស័យដែលជាចន្ទល់កំណើនសេដ្ឋកិច្ច ស្របតាមការចង្អុលបង្ហាញនៅក្នុង **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**; និង

(៣). សម្រេចឱ្យបាននូវរាល់គោលដៅអាទិភាពក្រោមរបៀបវារៈគោលនយោបាយ ដែលបានដាក់ចេញក្នុងអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ ឆ្នាំដោយឆ្នាំ ២០២៣ ជាឆ្នាំចុងក្រោយនៃអាណត្តិនេះ ។

**៣៩.** ចំណាយវិនិយោគ ដែលរួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង នឹងក្លាយជាអាទិភាពមួយផ្នែកទៀត ដែលរាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ និងបង្កើនការវិភាជធនធានបន្ថែម ក្នុងន័យជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង ដើម្បីផ្តល់សម្ទុះបន្ថែមដល់កិច្ចអភិវឌ្ឍន៍សង្គមកម្ពុជា និងចូលរួមកសាងមូលដ្ឋានសេដ្ឋកិច្ចរឹងមាំនាពេលខាងមុខ ។ ចំពោះចំណាយចរន្ត, ការបង្កើនឡើងវិញនូវចំណាយបន្ទុកបុគ្គលិកក៏ជាអាទិភាពផងដែរ ដើម្បីលើកកម្ពស់ជីវភាពមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ខណៈចំណាយក្រៅបន្ទុកបុគ្គលិកត្រូវបានបង្កើននៅលើមូលដ្ឋានដែលបានធ្វើវិចារណកម្មរួច និងសម្រាប់តែការអនុវត្តគោលនយោបាយអាទិភាពថ្មីៗ និងការត្រៀមបម្រុងសម្រាប់ដោះស្រាយហានិភ័យនានានៃជវភាពសេដ្ឋកិច្ចតែប៉ុណ្ណោះ ។

**៤០.** ដើម្បីឈានទៅសម្រេចគោលបំណងនៃក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ, រាជរដ្ឋាភិបាលកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ដូចខាងក្រោម÷

- ចំណូលក្នុងស្រុកសរុបត្រូវបានគ្រោងប្រមាណ ២១,៨៩%នៃ ផសស ក្នុងនោះ÷
    - ចំណូលចរន្តត្រូវបានគ្រោងសម្រេចឱ្យបានក្នុងទំហំ ២១,៦៤% នៃ ផសស និងមានកំណើន ១៣,៥% ធៀបនឹងការប៉ាន់ស្មានចំណូលចរន្តក្នុងឆ្នាំ ២០២២ ឬ ១៧,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ១៩,៦៩% នៃ ផសស និងថ្នាក់ក្រោមជាតិប្រមាណ ១,៩៥% នៃ ផសស ។
    - សម្រាប់ការប្រមូលចំណូលតាមអគ្គនាយកដ្ឋាន÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៨,៤៨% នៃ ផសស, អគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ១១,០០% នៃ ផសស និង ចំណូលមិនមែនសារពើពន្ធ ត្រូវគ្រោងសម្រេចឱ្យបាន ២,១៦% នៃ ផសស ។
    - ចំណូលមូលធនក្នុងស្រុកត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ០,២៥% នៃ ផសស ។
- ចំណាយសរុបថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ២៩,៤៣% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិមានប្រមាណ ២៧,៤៨% នៃ ផសស និង ចំណាយសរុបថវិកាថ្នាក់ក្រោមជាតិប្រមាណ ២,៩៥% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ១,០០% នៃ ផសស ។
    - ចំណាយចរន្តថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ១៧,៦៥% នៃ ផសស ដែលក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៤,៤% នៃចំណាយចរន្តសរុប ត្រូវជា ៧,៨៥% នៃ ផសស និងចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៥,៦% នៃចំណាយចរន្តសរុប ត្រូវជា ៩,៨១% នៃ ផសស ។
    - ចំណាយមូលធនត្រូវបានគ្រោងក្នុងរង្វង់ ១១,៧៨% នៃ ផសស ដែលក្នុងនោះ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៥,៨១% នៃ ផសស និង ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៤,៧០% នៃ ផសស ។

**៤១.** ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនសម្រាប់ឆ្នាំ ២០២៣ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

- **ចំណាយវិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៧៥% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត ពិសេសការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ ២០២១-២០២៣, ការអនុវត្តច្បាប់ស្តីពី

វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងការធានាភាពជោគជ័យនៃកិច្ចដំណើរការការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ឆ្នាំ ២០២៣ ។

- **ចំណាយវិស័យការពារជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៩១% នៃ ផសស សំដៅគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងការពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ។
- **ចំណាយវិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៨,២៥% នៃ ផសស សំដៅបន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការទទួលបានសេវាសុខាភិបាល, ពង្រឹងប្រព័ន្ធសុខភាពសាធារណៈ ដែលអាចឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, អនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩, បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំ, ព្រមទាំង គាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥, និងគោលនយោបាយអាទិភាពផ្សេងទៀត លើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន ជាពិសេសការប្រែប្រួលអាកាសធាតុ, និងធានាភាពជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំការប្រកួតកីឡា SEA Games-ASEAN Para Games ឆ្នាំ ២០២៣ ។
- **ចំណាយវិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,១១% នៃ ផសស ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ២០២១-២០៣០, និង ការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥, ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥ និង ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥ ។
- **ចំណាយផ្សេងៗ** ត្រូវបានគ្រោងប្រមាណ ៦,៤៥% នៃ ផសស ដើម្បីធានាបាននូវលទ្ធភាពអន្តរាគមន៍ភ្លាមៗ ក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ជាដើម ។ ដោយឡែក, សម្រាប់

ការអនុវត្តជាក់ស្តែង ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ ។

**៤២.** ដោយឈរលើមូលដ្ឋានក្របខណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្ត សម្រាប់ឆ្នាំ ២០២៣ នឹងស្ថិតក្នុងរង្វង់ ៣,៩៩% នៃ ផសស និង ឱនភាពថវិកាសរុប ស្ថិតក្នុងរង្វង់ -៧,៥៤% នៃ ផសស (សូមពិនិត្យក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១-២០២៥ ក្នុងឧបសម្ព័ន្ធ ២ ភ្ជាប់មកជាមួយ) ។

## ៤.១ វិធានការផ្នែកចំណូល

**៤៣.** ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាលើការប្រមូលចំណូល សំដៅទ្រទ្រង់ចលនការនៃការគាំទ្រដវភាពកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលនឹងការជំរុញការអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ជាពិសេស បន្តពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល មានជាអាទិ៍ ការកសាងក្របខណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល, ការកែលម្អគោលនយោបាយអាករពិសេស និងការសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជា ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធចំណូលរដ្ឋដែលអាចឆ្លើយតបបានទៅនឹងការវិវត្តនៃសង្គម-សេដ្ឋកិច្ច ព្រមទាំង ធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព, យុត្តិធម៌ និងសមធម៌សង្គម ។ ជាមួយគ្នានេះ, វិធានការគន្លឹះបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម÷

### ក. វិធានការផ្នែកពន្ធដារ

**៤៤.** វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៣ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន÷

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តនានា និងដាក់ចេញនូវវិធានការចាំបាច់បន្ថែមទៀតដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩,
- ពង្រឹងការប្រមូលចំណូលតាមវិស័យដែលនៅមានសក្តានុពល ដូចជា វិស័យសំណង់, វិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យផលិតស្រាបៀរ, ភេសជ្ជៈ និងថ្នាំជក់ ជាដើម,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, និង ពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា,
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,

- បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម ដែលមានភាពប្រឡាក់ក្រឡា, ស្វ័យប្រវត្តិកម្មពេញលេញ និង ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ, និង
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ ។

## ខ. វិធានការផ្នែកគយ និងរដ្ឋាករ

**៤៥.** វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៣ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម ÷

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម,
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់ធុរជន,
- បន្តបង្កើនចំនួនធុរជនមានអនុលោមភាពខ្ពស់ និងជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (Authorized Economic Operator- AEO), និង
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ និងតភ្ជាប់បញ្ជរតែមួយជាតិកម្ពុជាទៅនឹងបញ្ជរតែមួយអាស៊ាន ។

## គ. វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

**៤៦.** ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ,
- ជំរុញការដាក់ឱ្យអនុវត្ត និងពង្រីកវិសាលភាពប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) នៅរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់,
- ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើទំហំក្នុងកិច្ចសន្យាស្របតាមគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល,

- ជំរុញការបង់ចំណូលដីសម្បទានសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធអេឡិចត្រូនិក និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ច ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពិនិត្យកែសម្រួលអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីបង់សួយសារ,
- បន្តតាមដាន និងគ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈការពិនិត្យលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ជាមួយក្រសួងសាមី និងស្ថាប័នពាក់ព័ន្ធ, និង
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល ។

## ៤.២ វិធានការផ្នែកចំណាយ

**៤៧.** ដើម្បីសម្រេចឱ្យបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងទ្រទ្រង់ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពវិភាជន៍ ក៏ដូចជាប្រតិបត្តិការ និងការឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការសំខាន់ៗ ដូចខាងក្រោម÷

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងការដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩ និងគាំទ្រជីវភាពប្រជាពលរដ្ឋងាយរងគ្រោះដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និង ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី សម្រាប់ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបាននូវភាពធន់ ប្រកបដោយបរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល,
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ,

- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ជាពិសេស វិស័យបង្កើនផលិតភាព, ជំរុញការតភ្ជាប់ និង លើកកម្ពស់សមត្ថភាពប្រកួតប្រជែង, និង
- បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់នានា និងគោលនយោបាយអាទិភាព ដែលរួមមាន ការពង្រឹង ក). ការរៀបចំក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៣-២០២៥, ខ). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, គ). ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, ឃ). ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣, ង). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥ និង ច). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៩-២០២៥ ។

## ៥. សេចក្តីសន្និដ្ឋាន

**៤៨.** សម្រាប់ឆ្នាំ ២០២៣ និងរយៈពេលមធ្យមខាងមុខ, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជានឹងស្ថិតក្នុងនិន្នាការសុទិដ្ឋិនិយម ដែលរំពឹងថានឹងសម្រេចបានកំណើនខ្ពស់ ដោយសារ **(១). កត្តាខាងក្រៅ** ដែលឆ្លុះបញ្ចាំងពីតម្រូវការខាងក្រៅ តាមរយៈការរំពឹងទុកនូវការងើបឡើងវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ទាំងក្នុងតំបន់ និងសកលដោយសារការគ្រប់គ្រងបានល្អប្រសើរនូវស្ថានភាពជំងឺកូវីដ-១៩ ជាពិសេស ការចែកចាយ និងការចាក់វ៉ាក់សាំងកូវីដ-១៩នៅតាមបណ្តាប្រទេស និងទីតាំងភូមិសាស្ត្រទូទាំងសកលលោក ព្រមទាំងការបន្តអនុវត្តគោលនយោបាយគាំទ្រកំណើនពីបណ្តាប្រទេសអភិវឌ្ឍន៍ និង **(២). កត្តាខាងក្នុង** ដែលឆ្លុះបញ្ចាំងពីសមត្ថភាពរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ ប្រកបដោយភាពម៉ឺងម៉ាត់ និងប្រាកដនិយម ជាពិសេស ការសម្រេចបាននូវអត្រាគ្របដណ្តប់ខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញ ជូនប្រជាពលរដ្ឋទូទាំងប្រទេស និងការកែទម្រង់ ទាំងក្នុងទិដ្ឋភាពរដ្ឋបាល និងគោលនយោបាយ សំដៅធ្វើឱ្យល្អប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម, ការវិនិយោគ និងធុរកិច្ច ព្រមទាំងការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្ម ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិផងដែរ ។ ផ្អែកលើទស្សនវិស័យនេះ, កំណើនសេដ្ឋកិច្ចជាតិក្នុងឆ្នាំ ២០២៣ រំពឹងថានឹងសម្រេចបានក្នុងអត្រា ៦,៦% ជាមួយនឹងអត្រាអតិផរណាអាចគ្រប់គ្រងបានក្នុងរង្វង់ ២,៥% និងការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ។

**៤៩.** ដើម្បីគាំទ្រដល់ទស្សនវិស័យសេដ្ឋកិច្ចខាងលើ, ក្របខណ្ឌចំណូល-ចំណាយឆ្នាំ ២០២៣ ត្រូវបានរៀបចំប្រកបដោយភាពប្រយ័ត្នប្រយែង និងបុរេសកម្មខ្ពស់ ដែលឱនភាពថវិកាស្ថិតក្នុងរង្វង់ -៧,៥៤% នៃ ផសសក្នុងគោលដៅធានានូវភាពរឹងមាំ និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ជាមួយគ្នានេះ, ការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុសាធារណៈ នឹងឈរលើគោលការណ៍÷ (១). វិន័យ និងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការពោលគឺ ការចាយវាយឱ្យចំទិសដៅ ហើយផ្តោតលើតម្លៃនៃលុយ និង (២). ប្រសិទ្ធភាព និងតម្លាភាពនៃការកៀរគរ

ចំណូល ពោលគឺ ការបន្តធ្វើទំនើបកម្មប្រព័ន្ធចំណូល និងការផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈខ្ពស់ ដោយផ្តោតលើប្រភពចំណូលមានសក្តានុពល ដែលមានផលប៉ះពាល់សេដ្ឋកិច្ចតិចតួច ។

**៥០.** ជារួម, ផ្អែកលើការដកពិសោធន៍ពីវិបត្តិជំងឺកូវីដ-១៩ ក្នុងអំឡុងជាងពីរឆ្នាំកន្លងមក, រាជរដ្ឋាភិបាលនឹងខិតខំពន្លឿនកម្មវិធីកែទម្រង់សំខាន់ៗ និងដាក់ចេញវិធានការកែទម្រង់មុតស្រួចបន្ថែម ព្រមទាំងវិធានការគាំទ្រជាបន្តបន្ទាប់តាមតម្រូវការជាក់ស្តែង សំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឡើងវិញឱ្យបានឆាប់រហ័ស តាមរយៈការលើកកម្ពស់ និងជំរុញវិស័យឯកជន ទាំងក្នុងសកម្មភាពធុរកិច្ច, ពាណិជ្ជកម្ម និងវិនិយោគ ក្នុងការចាប់យកកាលានុវត្តភាពថ្មីៗ ដែលកើតចេញពីការប្រែប្រួលនិន្នាការនានា ជាពិសេស ការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មខ្សែច្រវាក់ផលិតកម្ម និងការកើនឡើងនូវការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿន និងបច្ចេកវិទ្យាឌីជីថល ទាំងក្នុង ក្របខណ្ឌប្រទេស, តំបន់ និងសកល ។ ក្នុងបរិការណ៍ដែលឆ្នាំ ២០២៣ ជាឆ្នាំចុងក្រោយនៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា, វឌ្ឍនភាពការងារដែលនឹងសម្រេចបាន រំពឹងថានឹងចូលរួមពង្រីកនិងពង្រឹងមាគ៌ាអភិវឌ្ឍជាតិឱ្យកាន់តែមានភាពរឹងមាំ, ជាពិសេស ផ្តល់ជាមូលដ្ឋានមួយប្រកបដោយភាពធន់ សម្រាប់ការបន្តជំរុញការអភិវឌ្ឍសម្រាប់អាណត្តិក្រោយ ។

❋❋❋✧❋❋❋

## ឧបសម្ព័ន្ធ ១៖ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច (២០១៩-២០២៥)

| សូចនាករម៉ាក្រូសេដ្ឋកិច្ច | 2019 | 2020 | 2021 | 2022ប. | 2023ព្យ. | 2024ព្យ. | 2025ព្យ. |
|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | **110,014** | **105,892** | **110,506** | **120,310** | **131,265** | **144,699** | **159,968** |
| ផសស សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | 1,700 | 1,605 | 1,659 | 1,785 | 1,924 | 2,096 | 2,281 |
| កំណើន ផសស ពិត (%) | **7.1%** | **-3.1%** | **3.0%** | **5.4%** | **6.6%** | **7.0%** | **7.3%** |
| អត្រាបរិត្តិផរណា ផសស (កំណើនប្រចាំឆ្នាំ) | 3.2% | -0.7% | 1.3% | 3.3% | 2.4% | 3.0% | 3.0% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 1.8% | 2.9% | 2.9% | 5.0% | 2.5% | 3.0% | 3.0% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក) | 4,055 | 4,080 | 4,068 | 4,065 | 4,065 | 4,065 | 4,065 |
| ការនាំចេញ (%នៃ ផសស) | 55.2% | 71.4% | 71.7% | 79.1% | 84.7% | 90.0% | 95.2% |
| ការនាំចូល (%នៃ ផសស) | 82.0% | 81.2% | 113.1% | 104.7% | 100.8% | 104.9% | 109.1% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -26.7% | -9.8% | -41.4% | -25.6% | -16.1% | -15.0% | -13.9% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ)(%នៃ ផសស) | -15.0% | -8.5% | -45.4% | -26.8% | -14.1% | -11.3% | -9.0% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 18,763 | 21,334 | 20,265 | 21,271 | 22,155 | 23,078 | 23,958 |
| ចំនួនខែនៃការនាំចូល | 8.8 | 13.4 | 7.4 | 7.7 | 7.6 | 6.9 | 6.3 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០២១) និងការប៉ាន់ស្មាន និងព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២២-២០២៥)

## ឧបសម្ព័ន្ធ ២ : ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ២០២១-២០២៣

*ផសស តាមថ្លៃបន្ទាន់ឆ្នាំ ២០២១ (ប៉ាន់ស្មាន)* 110,506
*ផសស តាមថ្លៃបន្ទាន់ឆ្នាំ ២០២២ (គម្រោង)* 120,312
*ផសស តាមថ្លៃបន្ទាន់ឆ្នាំ ២០២៣ (គម្រោង)* 131,276
*ឯកតា៖ ប៊ីលានរៀល*

| ចំណូល-ចំណាយ | ២០២១ | | | | | ២០២២ | | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ | បណ្ដោះអាសន្ន (*) | បណ្ដោះ. %២០២១ច្ប. | បណ្ដោះ. %២០២០ | បណ្ដោះ. %ផសស | ច្បាប់ | កែតម្រូវ | កែ. %២០២២ច្ប. | កែ. %២០២១ប. | កែ. %ផសស | គម្រោង | %២០២២កែ. | %២០២២ច្ប | %ផសស |
| **ចំណូលក្នុងប្រទេសសរុប** | **21,446** | **22,688** | **105.8%** | **95.4%** | **20.53%** | **25,594** | **26,314** | **102.8%** | **116.0%** | **21.87%** | **28,742** | **109.2%** | **112.3%** | **21.89%** |
| ចំណូលចរន្ត | 21,224 | 22,631 | 106.6% | 95.9% | 20.48% | 24,289 | 25,033 | 103.1% | 110.6% | 20.81% | 28,410 | 113.5% | 117.0% | 21.64% |
| ចំណូលមូលធន | 221 | 57 | 25.7% | 30.7% | 0.05% | 1,305 | 1,281 | 98.1% | 2252.0% | 1.06% | 332 | 25.9% | 25.4% | 0.25% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | | |
| **ចំណូលចរន្ត** | **19,706** | **20,326** | **103.1%** | **94.9%** | **18.39%** | **22,157** | **22,545** | **101.7%** | **110.9%** | **18.74%** | **25,845** | **114.6%** | **116.6%** | **19.69%** |
| ចំណូលសារពើពន្ធ | 17,520 | 18,433 | 105.2% | 95.4% | 16.68% | 20,227 | 20,593 | 101.8% | 111.7% | 17.12% | 23,399 | 113.6% | 115.7% | 17.82% |
| ចំណូលមិនមែនសារពើពន្ធ | 2,186 | 1,893 | 86.6% | 90.5% | 1.71% | 1,930 | 1,951 | 101.1% | 103.1% | 1.62% | 2,446 | 125.3% | 126.7% | 1.86% |
| **ចំណូលមូលធន** | **221** | **57** | **25.7%** | **30.7%** | **0.05%** | **1,305** | **1,281** | **98.1%** | **2252.0%** | **1.06%** | **332** | **25.9%** | **25.4%** | **0.25%** |
| **ថ្នាក់ក្រោមជាតិ** | | | | | | | | | | | | | | |
| **ចំណូលចរន្ត** | **1,518** | **2,305** | **151.8%** | **106.0%** | **2.09%** | **2,132** | **2,488** | **116.7%** | **107.9%** | **2.07%** | **2,565** | **103.1%** | **120.3%** | **1.95%** |
| ចំណូលសារពើពន្ធ | 1,050 | 1,791 | 170.5% | 92.2% | 1.62% | 1,584 | 1,915 | 120.9% | 107.0% | 1.59% | 2,172 | 113.4% | 137.1% | 1.65% |
| ចំណូលមិនមែនសារពើពន្ធ | 468 | 515 | 110.0% | 221.0% | 0.47% | 548 | 573 | 104.6% | 111.3% | 0.48% | 393 | 68.6% | 71.7% | 0.30% |
| **ចំណូលតាមអគ្គនាយកដ្ឋាន** | | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 9,074 | 11,083 | 122.1% | 95.5% | 10.03% | 11,411 | 12,673 | 111.1% | 114.3% | 10.53% | 14,434 | 113.9% | 126.5% | 11.00% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 9,496 | 9,141 | 96.3% | 94.5% | 8.27% | 10,400 | 9,836 | 94.6% | 107.6% | 8.18% | 11,137 | 113.2% | 107.1% | 8.48% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,654 | 2,408 | 90.7% | 103.6% | 2.18% | 2,478 | 2,524 | 101.9% | 104.8% | 2.10% | 2,839 | 112.5% | 114.6% | 2.16% |

| ចំណូល-ចំណាយ | ២០២១ | | | | | ២០២២ | | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ | បណ្ដោះអាសន្ន (*) | បណ្ដោះ. %២០២១ច្បា. | បណ្ដោះ. %២០២០ | បណ្ដោះ. %ផសស | ច្បាប់ | កែតម្រូវ | កែ. %២០២២ច្បា. | កែ. %២០២១ប. | កែ. %ផសស | គម្រោង | %២០២២កែ. | %២០២២ច្បា | %ផសស |
| **ចំណាយសរុប** | **32,010** | **34,906** | **109.0%** | **111.1%** | **31.59%** | **34,709** | **34,643** | **99.8%** | **99.2%** | **28.79%** | **38,636** | **111.5%** | **111.3%** | **29.43%** |
| ចំណាយចរន្ត | 18,751 | 21,795 | 116.2% | 115.9% | 19.72% | 20,850 | 20,889 | 100.2% | 95.8% | 17.36% | 23,173 | 110.9% | 111.1% | 17.65% |
| ចំណាយមូលធន | 13,259 | 13,111 | 98.9% | 104.0% | 11.86% | 13,858 | 13,754 | 99.2% | 104.9% | 11.43% | 15,463 | 112.4% | 111.6% | 11.78% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | | |
| **ចំណាយចរន្ត** | **17,447** | **19,704** | **112.9%** | **113.6%** | **17.83%** | **19,112** | **18,794** | **98.3%** | **95.4%** | **15.62%** | **21,121** | **112.4%** | **110.5%** | **16.09%** |
| **ចំណាយមូលធន** | **11,859** | **11,713** | **98.8%** | **105.8%** | **10.60%** | **11,988** | **11,889** | **99.2%** | **101.5%** | **9.88%** | **13,291** | **111.8%** | **110.9%** | **10.12%** |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 6,394 | 6,520 | 102.0% | 110.7% | 5.90% | 6,174 | 6,174 | 100.0% | 94.7% | 5.13% | 7,117 | 115.3% | 115.3% | 5.42% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 5,466 | 5,192 | 95.0% | 100.1% | 4.70% | 5,813 | 5,715 | 98.3% | 110.1% | 4.75% | 6,173 | 108.0% | 106.2% | 4.70% |
| **ថ្នាក់ក្រោមជាតិ** | | | | | | | | | | | | | | |
| ចំណាយចរន្ត | 2,365 | 3,163 | 133.7% | 131.1% | 2.86% | 3,002 | 3,358 | 111.9% | 106.2% | 2.79% | 3,359 | 100.0% | 111.9% | 2.56% |
| ចំណាយមូលធន | 214 | 214 | 100.0% | 48.1% | 0.19% | 393 | 393 | 100.0% | 183.5% | 0.33% | 513 | 130.5% | 130.5% | 0.39% |
| **ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** | 1,060 | 1,072 | 101.1% | 113.1% | 0.97% | 1,263 | 1,263 | 100.0% | 117.9% | 1.05% | 1,307 | 103.5% | 103.5% | 1.00% |
| **តុល្យភាព** | | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 2,473 | 836 | 33.8% | 17.5% | 0.76% | 3,439 | 4,143 | 120.5% | 495.4% | 3.44% | 5,237 | 126.4% | 152.3% | 3.99% |
| ឱនភាពសរុប | (10,564) | (12,217) | 115.7% | 160.1% | -11.06% | (9,114) | (8,330) | 91.4% | 68.2% | -6.92% | (9,894) | 118.8% | 108.6% | -7.54% |
| **ហិរញ្ញប្បទានឱនភាព** | **10,564** | **12,217** | **115.7%** | **160.1%** | **11.06%** | **9,114** | **8,330** | **91.4%** | **68.2%** | **6.92%** | **9,894** | **118.8%** | **108.6%** | **7.54%** |
| ក្នុងប្រទេស | 3,056 | 4,770 | 156.1% | -1380.5% | 4.32% | 555 | (790) | -142.4% | -16.6% | -0.66% | 779 | -98.6% | 140.3% | 0.59% |
| ក្រៅប្រទេស | 7,508 | 7,448 | 99.2% | 93.4% | 6.74% | 8,559 | 9,120 | 106.5% | 122.5% | 7.58% | 9,116 | 100.0% | 106.5% | 6.94% |
| ទ្រទ្រង់ថវិកាដោយដៃគូអភិវឌ្ឍន៍ | 858 | 1,071 | 124.9% | 62.8% | 0.97% | 1,268 | 1,933 | 152.4% | 180.4% | 1.61% | 1,283 | 66.4% | 101.1% | 0.98% |
| មូលធនក្រៅប្រទេស | 5,466 | 5,192 | 95.0% | 100.1% | 4.70% | 5,813 | 5,715 | 98.3% | 110.1% | 4.75% | 6,173 | 108.0% | 106.2% | 4.70% |
| ការទូទាត់ប្រាក់កម្ចី | 1,185 | 1,184 | 99.9% | 109.4% | 1.07% | 1,478 | 1,472 | 99.6% | 124.3% | 1.22% | 1,660 | 112.8% | 112.3% | 1.26% |

*(*) សម្គាល់៖ តួលេខបណ្ដោះអាសន្នគិតត្រឹមថ្ងៃ ២៩ ខែមេសា ឆ្នាំ ២០២២*

## ខ. ក្របខណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០២២-២០២៥

| ប៊ីលានរៀល | 2021 បណ្ដោះ. | 2022 ច្ប. | 2022 កែ. | 2023 ព្យ. | 2024 ព្យ. | 2025 ព្យ. |
|---|---|---|---|---|---|---|
| ចំណាយបន្ទុកបុគ្គលិកជា %នៃចំណាយចរន្តសរុប | 41.8% | 45.2% | 45.2% | 44.4% | 44.6% | 45.2% |
| I. ចំណូលក្នុងស្រុក | 22,688 | 25,594 | 26,314 | 28,742 | 32,392 | 36,426 |
| I.1 ចំណូលចរន្តសរុប | 22,631 | 24,289 | 25,033 | 28,410 | 32,031 | 36,001 |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 9,141 | 10,400 | 9,836 | 11,137 | 12,539 | 14,086 |
| អគ្គនាយកដ្ឋានពន្ធដារ | 11,083 | 11,411 | 12,673 | 14,434 | 16,309 | 18,347 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,408 | 2,478 | 2,524 | 2,839 | 3,184 | 3,568 |
| I.2 ចំណូលមូលធន | 57 | 1,305 | 1,281 | 332 | 361 | 425 |
| II. ចំណាយសរុប | 34,906 | 34,709 | 34,643 | 38,636 | 40,044 | 42,631 |
| II.1 ចំណាយចរន្តសរុប | 21,795 | 20,850 | 20,889 | 23,173 | 25,532 | 27,950 |
| បន្ទុកបុគ្គលិក | 9,120 | 9,434 | 9,434 | 10,299 | 11,391 | 12,633 |
| បន្ទុកមិនមែនបុគ្គលិក | 12,675 | 11,417 | 11,456 | 12,873 | 14,141 | 15,316 |
| II.2 ចំណាយមូលធនសរុប | 13,111 | 13,858 | 13,754 | 15,463 | 14,512 | 14,682 |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | 6,734 | 6,567 | 6,567 | 7,630 | 6,106 | 6,746 |
| ការទូទាត់ប្រាក់កម្ចី | 1,184 | 1,478 | 1,472 | 1,660 | 1,833 | 2,077 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,192 | 5,813 | 5,715 | 6,173 | 6,574 | 5,859 |
| III. អតិរេកចរន្ត | 836 | 3,439 | 4,143 | 5,237 | 6,499 | 8,051 |
| IV. ឱនភាព/អតិរេកសរុប | (12,217) | (9,114) | (8,330) | (9,894) | (7,652) | (6,205) |
| **កំណើនប្រចាំឆ្នាំ** | **2021 ប./ 2020** | **2022 ច្ប./ 2021 ប.** | **2022 កែ./ 2021 ប.** | **2023 ព្យ.** | **2024 ព្យ.** | **2025 ព្យ.** |
| I. ចំណូលក្នុងស្រុក | -4.6% | 12.8% | 16.0% | 9.2% | 12.7% | 12.5% |
| I.1 ចំណូលចរន្តសរុប | -4.1% | 7.3% | 10.6% | 13.5% | 12.7% | 12.4% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | -5.5% | 13.8% | 7.6% | 13.2% | 12.6% | 12.3% |
| អគ្គនាយកដ្ឋានពន្ធដារ | -4.5% | 3.0% | 14.3% | 13.9% | 13.0% | 12.5% |
| ចំណូលមិនមែនសារពើពន្ធសរុប | 3.6% | 2.9% | 4.8% | 12.5% | 12.2% | 12.1% |
| I.2 ចំណូលមូលធន | -69.3% | 2194.7% | 2152.0% | -74.1% | 8.7% | 17.9% |
| II. ចំណាយសរុប | 11.1% | -0.6% | -0.8% | 11.5% | 3.6% | 6.5% |
| II.1 ចំណាយចរន្តសរុប | 15.9% | -4.3% | -4.2% | 10.9% | 10.2% | 9.5% |
| បន្ទុកបុគ្គលិក | -1.2% | 3.4% | 3.4% | 9.2% | 10.6% | 10.9% |
| បន្ទុកមិនមែនបុគ្គលិក | 32.3% | -9.9% | -9.6% | 12.4% | 9.9% | 8.3% |
| II.2 ចំណាយមូលធនសរុប | 4.0% | 5.7% | 4.9% | 12.4% | -6.2% | 1.2% |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | *6.3%* | *-2.5%* | *-2.5%* | *16.2%* | *-20.0%* | *10.5%* |
| ការទូទាត់ប្រាក់កម្ចី | 9.4% | 24.8% | 24.3% | 12.8% | 10.4% | 13.3% |
| ហិរញ្ញប្បទានក្រៅប្រទេស | 0.1% | 12.0% | 10.1% | 8.0% | 6.5% | -10.9% |

| ផលធៀបនៃផ.ស.ស | 2021 បណ្ដោះ. | 2022 ថ្ប. | 2022 កែ. | 2023 ព្យ. | 2024 ព្យ. | 2025 ព្យ. |
|---|---|---|---|---|---|---|
| **I. ចំណូលក្នុងស្រុក** | **20.53%** | **23.16%** | **21.87%** | **21.89%** | **22.38%** | **22.77%** |
| **I.1 ចំណូលចរន្តសរុប** | **20.48%** | **21.98%** | **20.81%** | **21.64%** | **22.13%** | **22.50%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 8.27% | 9.41% | 8.18% | 8.48% | 8.66% | 8.80% |
| អគ្គនាយកដ្ឋានពន្ធដារ | 10.03% | 10.33% | 10.53% | 11.00% | 11.27% | 11.47% |
| ចំណូលមិនមែនសារពើពន្ធសរុប | 2.18% | 2.24% | 2.10% | 2.16% | 2.20% | 2.23% |
| **I.2 ចំណូលមូលធន** | **0.05%** | **1.18%** | **1.06%** | **0.25%** | **0.25%** | **0.27%** |
| **II. ចំណាយសរុប** | **31.59%** | **31.41%** | **28.79%** | **29.43%** | **27.67%** | **26.65%** |
| **II.1 ចំណាយចរន្តសរុប** | **19.72%** | **18.87%** | **17.36%** | **17.65%** | **17.64%** | **17.47%** |
| បន្ទុកបុគ្គលិក | 8.25% | 8.54% | 7.84% | 7.85% | 7.87% | 7.90% |
| បន្ទុកមិនមែនបុគ្គលិក | 11.47% | 10.33% | 9.52% | 9.81% | 9.77% | 9.57% |
| **II.2 ចំណាយមូលធនសរុប** | **11.86%** | **12.54%** | **11.43%** | **11.78%** | **10.03%** | **9.18%** |
| ហិរញ្ញប្បទាន ក្នុងប្រទេសសរុប | *6.09%* | *5.94%* | *5.46%* | *5.81%* | *4.22%* | *4.22%* |
| ការទូទាត់ប្រាក់កម្ចី | 1.07% | 1.34% | 1.22% | 1.26% | 1.27% | 1.30% |
| ហិរញ្ញប្បទាន ក្រៅប្រទេស | 4.70% | 5.26% | 4.75% | 4.70% | 4.54% | 3.66% |
| **III. អតិរេកចរន្ត** | **0.76%** | **3.11%** | **3.44%** | **3.99%** | **4.49%** | **5.03%** |
| **IV. ឱនភាព/អតិរេកសរុប** | **-11.06%** | **-8.25%** | **-6.92%** | **-7.54%** | **-5.29%** | **-3.88%** |

## គ. ចំណាយតាមវិស័យរយៈពេលមធ្យម ២០២២-២០២៥

| ចំណាយតាមវិស័យ (ប៊ីលានរៀល) | 2022 ច្ប. | 2022 ប៉ាន់. | 2023 គ្រ. | 2024 គ្រ. | 2025 គ្រ. |
|---|---|---|---|---|---|
| **1.1 ចំណាយថ្នាក់ជាតិ** | **32,577** | **32,156** | **36,071** | **37,279** | **39,538** |
| **ក.វិស័យរដ្ឋបាលទូទៅ** | **2,089** | **2,521** | **2,303** | **2,445** | **2,594** |
| ចំណាយចរន្ត | 1,916 | 2,348 | 1,998 | 2,092 | 2,197 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *694* | *694* | *739* | *795* | *860* |
| ចំណាយមូលធន | 173 | 173 | 305 | 353 | 397 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | - | - | *120* | *156* | *222* |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **4,795** | **4,796** | **5,139** | **5,662** | **6,266** |
| ចំណាយចរន្ត | 4,675 | 4,676 | 5,089 | 5,597 | 6,174 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3,823* | *3,823* | *4,197* | *4,663* | *5,197* |
| ចំណាយមូលធន | 120 | 120 | 50 | 65 | 92 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *23* | *23* | *50* | *65* | *92* |
| **គ.វិស័យសង្គមកិច្ច** | **8,450** | **9,336** | **10,829** | **11,266** | **12,549** |
| ចំណាយចរន្ត | 7,332 | 8,219 | 8,177 | 9,030 | 10,008 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3,611* | *3,611* | *3,948* | *4,369* | *4,851* |
| ចំណាយមូលធន | 1,118 | 1,118 | 2,652 | 2,236 | 2,541 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *110* | *110* | *2,220* | *1,776* | *2,131* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **6,532** | **6,436** | **9,327** | **9,364** | **9,219** |
| ចំណាយចរន្ត | 1,457 | 1,460 | 1,522 | 1,648 | 1,787 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *526* | *526* | *569* | *621* | *681* |
| ចំណាយមូលធន | 5,075 | 4,976 | 7,805 | 7,716 | 7,432 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *539* | *539* | *2,249* | *1,799* | *2,159* |
| **ង.ចំណាយផ្សេងៗ** | **10,711** | **9,066** | **8,473** | **8,542** | **8,910** |
| ចំណាយចរន្ត | 3,731 | 2,091 | 4,335 | 4,953 | 5,310 |
| ចំណាយមូលធន | 6,980 | 6,975 | 4,138 | 3,590 | 3,600 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *5,502* | *5,502* | *2,478* | *1,756* | *1,523* |
| **1.2 ចំណាយថ្នាក់ក្រោមជាតិ** | **3,395** | **3,751** | **3,872** | **4,290** | **4,820** |

| កំណើនប្រចាំឆ្នាំ | 2022 ច្ប./ 2021 ប. | 2022 ប៉ាន់./ 2021 ប. | 2023 គ្រ. | 2024 គ្រ. | 2025 គ្រ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ** | **-0.4%** | **-0.6%** | **11.5%** | **3.6%** | **6.5%** |
| **1.1 ចំណាយថ្នាក់ជាតិ** | **-0.1%** | **-1.4%** | **12.2%** | **3.3%** | **6.1%** |
| **ក.វិស័យរដ្ឋបាលទូទៅ** | **-25.5%** | **-10.0%** | **-8.7%** | **6.2%** | **6.1%** |
| ចំណាយចរន្ត | 0.0% | 22.6% | -14.9% | 4.7% | 5.0% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *7.1%* | *7.1%* | *6.5%* | *7.6%* | *8.1%* |
| ចំណាយមូលធន | -80.5% | -80.5% | 76.6% | 15.7% | 12.5% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | -100.0% | - | - | *30.0%* | *42.0%* |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **6.5%** | **6.5%** | **7.2%** | **10.2%** | **10.7%** |
| ចំណាយចរន្ត | 4.7% | 4.7% | 8.8% | 10.0% | 10.3% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *-0.3%* | *-0.3%* | *9.8%* | *11.1%* | *11.4%* |
| ចំណាយមូលធន | 222.6% | 222.6% | -58.3% | 30.0% | 42.0% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-39.1%* | *-39.1%* | *121.2%* | *30.0%* | *42.0%* |
| **គ.វិស័យសង្គមកិច្ច** | **-30.5%** | **-23.2%** | **16.0%** | **4.0%** | **11.4%** |
| ចំណាយចរន្ត | -28.6% | -20.0% | -0.5% | 10.4% | 10.8% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *6.1%* | *6.1%* | *9.3%* | *10.7%* | *11.0%* |
| ចំណាយមូលធន | -41.0% | -41.0% | 137.3% | -15.7% | 13.6% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-92.8%* | *-92.8%* | *1918.2%* | *-20.0%* | *20.0%* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **-13.4%** | **-14.7%** | **44.9%** | **0.4%** | **-1.5%** |
| ចំណាយចរន្ត | 14.3% | 14.5% | 4.2% | 8.3% | 8.4% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *10.7%* | *10.7%* | *8.0%* | *9.2%* | *9.7%* |
| ចំណាយមូលធន | -19.1% | -20.6% | 56.8% | -1.1% | -3.7% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-66.2%* | *-66.2%* | *317.3%* | *-20.0%* | *20.0%* |
| **ង.ចំណាយផ្សេងៗ** | **91.7%** | **62.3%** | **-6.5%** | **0.8%** | **4.3%** |
| ចំណាយចរន្ត | 109.9% | 17.7% | 107.3% | 14.3% | 7.2% |
| ចំណាយមូលធន | 83.3% | 83.1% | -40.7% | -13.3% | 0.3% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *109.6%* | *109.6%* | *-55.0%* | *-29.1%* | *-13.3%* |
| **1.2 ចំណាយថ្នាក់ក្រោមជាតិ** | **2.3%** | **13.0%** | **3.2%** | **10.8%** | **12.3%** |

| ផលធៀបនៃផ.ស.ស | 2022 ច្ប. | 2022 ប៉ាន់. | 2023 គ្រ. | 2024 គ្រ. | 2025 គ្រ. |
|---|---|---|---|---|---|
| **1.1 ចំណាយ ថ្នាក់ជាតិ** | **27.08%** | **26.73%** | **27.48%** | **25.76%** | **24.71%** |
| **ក.វិស័យរដ្ឋបាល ទូទៅ** | **1.74%** | **2.10%** | **1.75%** | **1.69%** | **1.62%** |
| ចំណាយចរន្ត | 1.59% | 1.95% | 1.52% | 1.45% | 1.37% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *0.58%* | *0.58%* | *0.56%* | *0.55%* | *0.54%* |
| ចំណាយមូលធន | 0.14% | 0.14% | 0.23% | 0.24% | 0.25% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.00%* | *0.00%* | *0.09%* | *0.11%* | *0.14%* |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **3.99%** | **3.99%** | **3.91%** | **3.91%** | **3.92%** |
| ចំណាយចរន្ត | 3.89% | 3.89% | 3.88% | 3.87% | 3.86% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3.18%* | *3.18%* | *3.20%* | *3.22%* | *3.25%* |
| ចំណាយមូលធន | 0.10% | 0.10% | 0.04% | 0.04% | 0.06% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.02%* | *0.02%* | *0.04%* | *0.04%* | *0.06%* |
| **គ.វិស័យសង្គមកិច្ច** | **7.02%** | **7.76%** | **8.25%** | **7.79%** | **7.84%** |
| ចំណាយចរន្ត | 6.09% | 6.83% | 6.23% | 6.24% | 6.26% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3.00%* | *3.00%* | *3.01%* | *3.02%* | *3.03%* |
| ចំណាយមូលធន | 0.93% | 0.93% | 2.02% | 1.55% | 1.59% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.09%* | *0.09%* | *1.69%* | *1.23%* | *1.33%* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **5.43%** | **5.35%** | **7.11%** | **6.47%** | **5.76%** |
| ចំណាយចរន្ត | 1.21% | 1.21% | 1.16% | 1.14% | 1.12% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *0.44%* | *0.44%* | *0.43%* | *0.43%* | *0.43%* |
| ចំណាយមូលធន | 4.22% | 4.14% | 5.95% | 5.33% | 4.65% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.45%* | *0.45%* | *1.71%* | *1.24%* | *1.35%* |
| **ង.ចំណាយ ផ្សេងៗ** | **8.90%** | **7.54%** | **6.45%** | **5.90%** | **5.57%** |
| ចំណាយចរន្ត | 3.10% | 1.74% | 3.30% | 3.42% | 3.32% |
| ចំណាយមូលធន | 5.80% | 5.80% | 3.15% | 2.48% | 2.25% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *4.57%* | *4.57%* | *1.89%* | *1.21%* | *0.95%* |
| **1.2 ចំណាយ ថ្នាក់ក្រោម ជាតិ** | **2.82%** | **3.12%** | **2.95%** | **2.96%** | **3.01%** |